ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 38

# ទ្រព្យសកម្មអរូបី
## Intangible Assets

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ "**ឈ្នះ-ឈ្នះ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**", "**យុទ្ធសាស្ត្រត្រីកោណ**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**" និង "**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា**" ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្ដើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន “*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរ្ញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស *លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ងី តាយី**

## គោលបំណង

១ គោលបំណងនៃស្តង់ដានេះគឺដាក់បញ្ញត្តិចំពោះការធ្វើគណនេយ្យកម្មទ្រព្យសកម្មអរូបិយដែលមិនពាក់ព័ន្ធជាមួយនឹងស្តង់ដាផ្សេងទៀតឡើយ ។ ស្តង់ដា នេះតម្រូវឱ្យអង្គភាពមួយធ្វើការទទួលស្គាល់ទ្រព្យសកម្មអរូបិយ ប្រសិនបើ និងតែប្រសិនបើ លក្ខណៈវិនិច្ឆ័យជាក់លាក់ត្រូវបានបំពេញ ។ ស្តង់ដានេះ ក៏បញ្ជាក់ផងដែរ ពីវិធីសាស្ត្រនៃការវាយតម្លៃទៅលើតម្លៃយោងនៃទ្រព្យសកម្មអរូបិយ និងតម្រូវឱ្យមានការលាតត្រដាងបង្ហាញជាក់លាក់អំពីទ្រព្យសកម្មអរូបិយនោះ ។

## វិសាលភាព

២ ស្តង់ដានេះ ត្រូវបានអនុវត្តនៅក្នុងគណនេយ្យកម្មលើទ្រព្យសកម្មអរូបិយ លើកលែងតែ ៖

ក. ទ្រព្យសកម្មអរូបិយ ស្ថិតនៅក្រោមវិសាលភាពនៃស្តង់ដាផ្សេងទៀត ។

ខ. ទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងស.គ.អ.ក៣២ *ឧបករណ៍ហិរញ្ញវត្ថុ: ការបង្ហាញ*

គ. ការទទួលស្គាល់ និងការវាស់វែងនៃការរុករករ៉ែ និងការវាយតម្លៃទ្រព្យសកម្ម (សូមមើល ស.រ.ហ.អ.ក ៦ *ការរុករក និងការវាយតម្លៃធនធានរ៉ែ* )។

## ឃ. ការចំណាយលើការអភិវឌ្ឍន៍ និងការទាញយករ៉ែ ប្រេងឧស្ម័ន ធម្មជាតិ និងធនធាន មិនកកើតឡើងវិញស្រដៀងគ្នា

៣ ប្រសិនបើស្តង់ដាមួយផ្សេងទៀតបានចែងអំពីគណនេយ្យកម្មសម្រាប់ ប្រភេទជាក់លាក់នៃទ្រព្យសកម្មអរូបិយ អង្គភាពមួយត្រូវអនុវត្តទៅតាមស្ត ង់- ដារនោះ ជំនួសឱ្យស្តង់ដានេះ ។ ជាឧទាហរណ៍ ស្តង់ដានេះមិនអនុវត្ត ចំពោះ ÷

ក. ទ្រព្យសកម្មអរូបិយដែលកាន់កាប់ដោយអង្គភាពសម្រាប់លក់ក្នុង ដំណើរការអាជីវកម្មធម្មតា (សូមមើលទៅស្តង់ដាស.គ.អ.ក២ *សន្និធិ* និង ស.គ.អ.ក ១១ *កិច្ចសន្យាសាងសង់*)។

ខ. ទ្រព្យសកម្មពន្ធពន្យា (សូមមើលទៅស្តង់ដាស.គ.អ.ក ១២ *ពន្ធលើប្រាក់ចំណូល*)

គ. ភតិសន្យាដែលនៅក្រោមវិសាលភាពនៃស.គ.អ.ក ១៧*ភតិសន្យា*

ឃ. ទ្រព្យសកម្មដែលកើតពីអត្ថប្រយោជន៍របស់និយោជិត (សូមមើល ស.គ.អ.ក ១៩ *អត្ថប្រយោជន៍របស់និយោជិត*)

ង. ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានក្នុង ស.គ.អ.ក៣២ ។ ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ ដែលស្ថិតនៅក្រោម ស.គ.អ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក* ស.គ.អ.ក ២៨ ការវិនិយោគក្នុងក្រុមហ៊ុនសមាគត និង ស.គ.អ.ក ៣១*ភាគកម្មក្នុងក្រុមហ៊ុនរួមទុន* ។

ច. មូលនិធិពាណិជ្ជកម្ម ដែលបានមកពីការរួមពាណិជ្ជកម្មបញ្ចូលគ្នា (សូមមើល ស.រ.ហ.អ.ក៣*ការបញ្ចូលអាជីវកម្មរួមគ្នា)*។

ឆ. ថ្លៃដើមទិញពន្យា និងទ្រព្យសកម្មអរូបិយដែលកើតឡើងពីសិទ្ធិតាម កិច្ចសន្យារបស់ក្រុមហ៊ុនធានារ៉ាប់រង ក្រោមកិច្ចសន្យាធានារ៉ាប់រង ដែលមានក្នុង ស.រ.ហ.អ.ក ៤ *កិច្ចសន្យាធានារ៉ាប់រង* ។ ស.រ.ហ.អ.ក ៤ កំណត់ឱ្យមានសេចក្តីតម្រូវចំពោះការលាតត្រដាងព័ត៌មានជាក់លាក់សម្រាប់ថ្លៃដើមទិញដែលបានពន្យាប៉ុន្តែមិនតម្រូវសម្រាប់ទ្រព្យសកម្មអរូបិយទាំងអស់នោះឡើយ ។ ដូច្នេះតម្រូវការបង្ហាញព័ត៌មានដែលមាននៅក្នុងស្តង់ដានេះអនុវចំពោះទ្រព្យសកម្មអរូបិយទាំងអស់នោះ ។

ជ. ទ្រព្យសកម្មអរូបិយរយៈពេលវែងដែលបានចាត់ថ្នាក់ជាទ្រព្យសម្រា-ប់លក់ (ឬ រួមបញ្ចូលទាំងក្រុមទ្រព្យសកម្មសម្រាប់លក់ចោលដែលថ្នាក់ជាទ្រព្យសកម្មសម្រាប់លក់ ) ដោយអនុលោមតាម ស.រ.ហ.អ.ក ៥ *ទ្រព្យសកម្មរយៈពេលវែងរក្សាទុកសម្រាប់លក់ និងប្រតិបត្តិការមិនបន្ត* ។

៤ ទ្រព្យសកម្មអរូបិយខ្លះអាចរួមមាន ធាតុសំខាន់ៗដែលមានរូបរាងដូចជា ឌីស តូចៗ (ក្នុងករណីផ្នែកទន់នៃកុំព្យូទ័រ) ឯកសារផ្លូវច្បាប់ (ក្នុងករណីជាអាជ្ញាប័ណ្ណ ឬប្រកាសនីយបត្រ) ឬខ្សែអាត់ ។ នៅក្នុងការកំណត់ថា តើទ្រព្យសកម្មមួយ ដែលរួមមានទាំងធាតុរូបិយនិងអរូបិយត្រូវបានកំណត់តាម ស.គ.អ.ក ១៦ *ទ្រព្យ រោងចក្រ និងបរិក្ខា* ឬក៏ជាទ្រព្យសកម្មអរូបិយដែលស្ថិត នៅក្រោមស្តង់ដានេះ ។ អង្គភាពប្រើការវិនិច្ឆ័យដើម្បីវាយតម្លៃធាតុណា មួយដែលមានសារសំខាន់ច្រើនជាង ។ ជាឧទាហរណ៍ផ្នែកទន់ នៃកំព្យូទ័រ សម្រាប់កុំព្យូទ័រសម្រាប់ឧបករណ៍ ដែលត្រួតពិនិត្យកុំព្យូទ័រដែលមិនអាច ដំណើរការដោយគ្មានផ្នែកទន់ដ៏ជាក់លាក់ គឺជាផ្នែកសំខាន់មួយនៃ

ផ្នែករឹង ទាក់ទិនហើយដែលបានចាត់ទុកថា ជាទ្រព្យ រោងចក្រ និងបរិក្ខារ។ ការអនុវត្ត ដូចគ្នាផងដែរចំពោះប្រព័ន្ធប្រតិបត្តិការនៃកុំព្យូទ័រ ។ ពេលដែលផ្នែកទន់នៃកុំព្យូទ័រ មិនមែនជាផ្នែកទាំងមូលនៃផ្នែករឹងដែលទាក់ទិនផ្នែកទន់របស់កុំព្យូទ័រត្រូវបានគេទទួលស្គាល់ជាទ្រព្យអរូបិយ ។

៥ នៅក្នុងចំណោមការចំណាយផ្សេងទៀតស្តង់ដានេះ អនុវត្តចំពោះការចំណាយ លើការផ្សព្វផ្សាយពាណិជ្ជកម្ម ការហ្វឹកហ្វឺន ការបង្កើតឡើង និងសកម្មភាពស្រាវជ្រាវ និងការអភិវឌ្ឍ។សកម្មភាពនៃការស្រាវជ្រាវ និងការអភិវឌ្ឍទាក់ទងដោយផ្ទាល់ជាមួយនឹងការអភិវឌ្ឍចំណេះដឹង ។ ហេតុដូច្នេះហើយទោះបីជាសកម្មភាពទាំងនេះ បង្កើតឱ្យមានធាតុដែលអាចមើលឃើញក៏ដោយ (ឧទាហរណ៍ គំរូដើម) ក៏ធាតុដែលមើលឃើញនោះគ្រាន់តែជាធាតុបន្ទាប់បន្សំប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងចំណេះវិជ្ជាមាននៅជាប់ជាមួយទ្រព្យសកម្មនោះ ។

៦ ក្នុងករណីនៃភតិសន្យាហិរញ្ញវត្ថុ ទ្រព្យសកម្មដើមអាចជារូបិយ និងអរូបិយ។ បន្ទាប់ពីការទទួលស្គាល់ដំបូង ភតិកៈធ្វើគណនេយ្យកម្មសម្រាប់ទ្រព្យសកម្មអរូបិយដែលបានរក្សាទុកក្រោមភតិសន្យាហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដានេះ ។ សិទ្ធិនៅក្រោមកិច្ចព្រមព្រៀងផ្តល់អាជ្ញាបណ្ណ សម្រាប់ធាតុដូចជា ហ្វីលរូបភាពខ្សែអាត់វីដេអូ ល្ខោន បទនិពន្ធប្រកាសនីយបត្រសិទ្ធិថតចំលង មិនស្ថិតនៅក្នុងវិសាលភាពនៃ ស.គ.អ.ក ១៧ តែស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដានេះដែរ ។

៧ ការដកចេញពីវិសាលភាពនៃស្តង់ដា អាចកើតមានឡើងប្រសិនបើសកម្ម-ភាព ឬ ប្រតិបត្តិការ ជាក់លាក់មានលក្ខណៈពិសេស ដែលអាចបង្កឱ្យមានបញ្ហាគណនេយ្យ ដែលត្រូវការមធ្យោបាយដោះស្រាយផ្សេងៗគ្នា ។ បញ្ហា

ទាំងនេះមានដូចជា ចំពោះការចំណាយទៅលើអាជីវកម្ម រុករករ៉ែការអភិវឌ្ឍ និងការទាញយកប្រេង ឧស្ម័ន និងស្រទាប់រ៉ែ ឧស្សាហកម្ម ទាញយករ៉ែ និងនៅក្នុងករណីនៃកិច្ចសន្យាធានារ៉ាប់រង ។ ហេតុដូច្នេះហើយស្តង់ដានេះមិនយកទៅអនុវត្តចំពោះការចំណាយលើសកម្មភាព និងកិច្ចសន្យាបែបនោះទេ ។ ប៉ុន្តែស្តង់ដានេះ អនុវត្តចំពោះទ្រព្យសកម្មអរូបិយ ផ្សេងៗដែលបានប្រើប្រាស់ (ដូចជាផ្នែកទន់នៃកុំព្យូទ័រ) និងការចំណាយ ផ្សេងៗ (ដូចជាចំណាយនៃការបង្កើតឡើង) ក្នុងឧស្សាហកម្ម ដែលទាញ យករ៉ែ ឬដោយក្រុមហ៊ុនធានារ៉ាប់រង

## និយមន័យ

៨ **វាក្យស័ព្ទខាងក្រោមនេះត្រូវបានប្រើនៅក្នុងស្តង់ដានេះដោយមានអត្ថន័យបញ្ជាក់ដូចតទៅៈ**

*ទីផ្សារសកម្ម* **ជាទីផ្សារមួយដែលលក្ខខណ្ឌខាងក្រោមទាំងអស់កើតមានៈ**

**ក. ធាតុដែលបានជួញដូរនៅក្នុងទីផ្សារ ឋិតនៅក្នុងប្រភេទតែមួយ។**

**ខ. អ្នកទិញ និងអ្នកលក់ដែលស្ម័គ្រស្មោះ ជាធម្មតាអាចត្រូវបាន រកឃើញគ្រប់ពេល**

**គ. តម្លៃមានសម្រាប់សាធារណៈជន**

*រំលស់* **គឺជាការបែងចែកជាប្រព័ន្ធនៃទឹកប្រាក់អាចដករំលស់បាននៃទ្រព្យសកម្មអរូបិយលើអាយុ កាលប្រើប្រាស់របស់វា។**

*ទ្រព្យសកម្ម* **គឺជាធនធាន ÷**

**ក. គ្រប់គ្រងដោយអង្គភាពមួយ ដែលកើតឡើងពីព្រឹត្តិការណ៍ អតីតកាលនិង**

ខ. អង្គភាពបានរំពឹងថា នឹងទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច នាពេលអនាគត។

*តម្លៃយោង* គឺជាទឹកប្រាក់ដែលទ្រព្យសកម្មមួយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុបន្ទាប់ពីការដកចេញនូវទឹកប្រាក់រំលស់បង្គរ និងការខាត់បង់ទៅលើការថយចុះនៃតម្លៃទ្រព្យសកម្មបង្គរ ។

*ថ្លៃដើម* គឺជាតម្លៃសាច់ប្រាក់ ឬសមមូលសាច់ប្រាក់ដែលបានចំណាយ ឬក៏តម្លៃសមស្របនៃតម្លៃតបស្នងដែលបានបោះបង់ ដើម្បីទិញទ្រព្យសកម្មមួយនាពេលទិញ ឬការសាងសង់ ឬនៅពេលអាចអនុវត្តបាន ចំនួនទឹកប្រាក់ដែលបានដាក់ចូលទៅក្នុងទ្រព្យសកម្ម ទទួលស្គាល់នៅលើកដំបូងតាមសេចក្ដីតម្រូវ ជាក់លាក់នៃ ស.រ.ហ.អ.ក ២*ទូទាត់ផ្អែកលើបណ្ណភាគហ៊ុន* ។

*តម្លៃដែលអាចដករំលស់បាន* គឺជាថ្លៃដើមរបស់ទ្រព្យសកម្ម ឬទឹកប្រាក់ដទៃទៀត ដែលត្រូវបានដាក់ជំនួសឱ្យថ្លៃដើម ដោយដកចេញនូវតម្លៃកាកសំណល់របស់វា។

*ការអភិវឌ្ឍ* គឺជាការអនុវត្តនៃការស្រាវជ្រាវរបកគំហើញថ្មីៗឬចំណេះដឹងផ្សេងៗទៀត ចំពោះផែនការ ឬការរចនាសម្រាប់ផលិតកម្មនៃសម្ភារៈឧបករណ៍ ផលិតផលដំណើរការប្រព័ន្ធ ឬ សេវាដែលមានលក្ខណៈល្អប្រសើរជាសំខាន់ មុនការចាប់ផ្តើមផលិតកម្មពាណិជ្ជកម្ម ឬ ប្រើប្រាស់ ។

*តម្លៃជាក់លាក់នៃអង្គភាព* គឺជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ ដែល អង្គភាពសង្ឃឹមថានឹងកើតឡើងពីការបន្តប្រើប្រាស់ទ្រព្យសកម្ម និងពី ការលក់នៅចុងអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម ឬសង្ឃឹមថានឹងកើត ឡើងនៅពេលទូទាត់បំណុល ។

*តម្លៃសមស្រប*គឺជាទឹកប្រាក់ដែលទ្រព្យសកម្មមួយ ដែលអាចត្រូវដោះដូរ ឬបំណុលដែលត្រូវទូទាត់រវាងភាគី ដែលមានឆន្ទៈ និងយល់ដឹងនៅក្នុង ប្រតិបត្តិការបើកចំហ។

*ការខាតបង់ដោយសារការស្រុតចុះតម្លៃ*គឺជាចំនួនទឹកប្រាក់មួយដែលតម្លៃយោងរបស់ទ្រព្យសកម្មខ្ពស់ជាងថ្លៃដែលអាចទទួលបានមកវិញ ។

*ទ្រព្យសកម្មអរូបិយ* គឺជាទ្រព្យសកម្មមិនមែនរូបិយវត្ថុដែលអាចកំណត់បានដោយគ្មានរូបរាងពិត។

*ទ្រព្យសកម្មរូបិយវត្ថុ* គឺជារូបិយវត្ថុដែលរក្សាទុក និងទ្រព្យសកម្មដែលត្រូវទទួលបានជាចំនួនទឹកប្រាក់រូបិយវត្ថុថេរ ឬអាចកំណត់បាន។

*ការស្រាវជ្រាវ* គឺជាការអង្កេតដែលបានរៀបចំជាមុន និងដំបូងបង្អស់ដែលត្រូវបានគេធ្វើឡើងជាមួយនឹងការសង្ឃឹមទុក នៃការទទួលបាននូវចំណេះដឹងបច្ចេកទេស និងវិទ្យាសាស្ត្រ ព្រមទាំងចំណេះដឹងថ្មីៗ ។

*តម្លៃកាកសំណល់*នៃទ្រព្យសកម្មអរូបិយ គឺជាតម្លៃប៉ាន់ស្មានដែលបច្ចុប្បន្នអង្គភាពរំពឹងថា នឹងទទួលបានពីការលក់ចោលនៃទ្រព្យសកម្ម បន្ទាប់ពី ដកចេញនូវថ្លៃដើមប៉ាន់ស្មាននៃការលក់ចោលប្រសិនបើទ្រព្យសកម្មនោះ ដល់អាយុកាល និងស្ថិតនៅក្នុងលក្ខខណ្ឌនៅចុងអាយុកាលប្រើប្រាស់របស់ ទ្រព្យសកម្មអរូបិយនោះ ។

*អាយុកាលប្រើប្រាស់* គឺជា៖

(ក) ការិយបរិច្ឆេទលើរយៈពេលមួយដែលទ្រព្យសកម្មត្រូវបានរំពឹងថានឹងត្រូវបានប្រើប្រាស់ដោយអង្គភាព ឬ

(ខ) ចំនួនឯកត្តាផលិតកម្ម ឬឯកត្តាស្រដៀងគ្នាដែលអង្គភាពបានរំពឹងថានឹងទទួលបានពីទ្រព្យសកម្មរបស់ខ្លួន។

## ទ្រព្យសកម្មអរូបិយ

៩ អង្គភាពជារឿយៗពង្រីកធនធានរបស់ខ្លួន ឬកើតមានបំណុលទៅលើការទិញ ការអភិវឌ្ឍ ការជួសជុលថែទាំ ការបង្កើនធនធានអរូបិយដូចជា ចំណេះ ខាងបច្ចេកទេស ឬវិទ្យាសាស្ត្រ ការរចនា ការអនុវត្តនៃដំណើរការ ឬប្រព័ន្ធ ថ្មីៗ អាជ្ញាបណ្ណ កម្មសិទ្ធិបញ្ញា ការយល់ដឹងពីទីផ្សារ និងស្លាកសញ្ញា ពាណិជ្ជកម្ម (រួមបញ្ចូលឈ្មោះម៉ាកផលិតផល និងចំណងជើងបោះពុម្ព ផ្សាយ )។ ឧទាហរណ៍រួមនៃធាតុទាំងនេះត្រូវបានរួមបញ្ចូល ដោយចំណង ជើងធំៗ គឺផ្នែកទន់របស់កុំព្យូទ័រ ប្រកាសនីយបត្រ សិទ្ធិថតចំលង ចំលងខ្សែភាពយន្ត បញ្ជីឈ្មោះអតិថិជនសិទ្ធិបម្រើសេវារបស់ដាក់បញ្ចាំ អាជ្ញាបណ្ណនេសាទ កូតានាំចូល សិទ្ធិធ្វើអាជីវកម្ម ទំនាក់ទំនងជាមួយ អតិថិជន ឬអ្នកផ្គត់ផ្គង់ ភាពស្មោះត្រង់របស់អតិថិជនចំណែកទីផ្សារ និង សិទ្ធិដាក់លក់ផលិតផល ។

១០ មិនមែនគ្រប់ធាតុដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ ៩ នឹងបំពេញទៅតាមនិយមន័យរបស់ទ្រព្យសកម្មអរូបិយទេ ពោលគឺភាពអាចកំណត់បានការ ត្រួតពិនិត្យលើធនធាន និងការកើតមាននៃ ផលប្រយោជន៍សេដ្ឋកិច្ចនា ពេលអនាគត ។ ប្រសិនបើធាតុមួយនៅក្នុងវិសាលភាពនៃស្តង់ដានេះមិន បំពេញទៅតាមនិយមន័យរបស់ទ្រព្យសកម្មអរូបិយទេនោះ ការចំណាយដើម្បី ទិញ ឬបង្កើតទ្រព្យសកម្មអរូបិយផ្ទៃក្នុងត្រូវបានទទួលស្គាល់ថា ជាចំណាយ ពេលដែលវាបានកើតមានឡើង ។ ទោះបីជាយ៉ាងណាប្រសិនបើធាតុ មួយបានទិញបញ្ចូលតាមរយៈការរួមអាជីវកម្មបញ្ចូលគ្នាមួយនោះ វាបង្កើត បានជាផ្នែកនៃមូលនិធិពាណិជ្ជកម្ម ដែលបានទទួលស្គាល់នៅត្រឹមកាល បរិច្ឆេទនៃការទិញនោះ ( សូមមើល កថាខណ្ឌ ៦៨) ។

**ភាពអាចកំណត់បាន**

១១ និយមន័យរបស់ទ្រព្យសកម្មអរូបិយតម្រូវថាទ្រព្យសកម្មអរូបិយមួយ ត្រូវតែអាច កំណត់បានដើម្បីញែកវាចេញពីមូលនិធិពាណិជ្ជកម្ម គឺជាទ្រព្យសកម្មអរូបិយ ដែលតំណាងឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលកើតចេញ ពីទ្រព្យសកម្មដែលបានទិញផ្សេងទៀតនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាដែលអាចកំណត់បានមួយៗ និងត្រូវបានទទួលស្គាល់ដាច់ដោយឡែក ។ អត្ថ- ប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត អាចកើតមកពីកម្លាំងមិនធម្មតារវាង ទ្រព្យសកម្មអាចកំណត់បាន ដែលត្រូវបានទិញចូល ឬក៏ពីទ្រព្យសកម្មនីមួយៗ ដែលមួយៗមិនទាន់បានបំពេញឱ្យការទទួលស្គាល់នៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុ ។

**១២** **ទ្រព្យសកម្មដែលអាចកំណត់បានប្រសិនៈ**

**(ក)** **អាចបំបែកពីគ្នាបាន ពោលគឺអាចបំបែក ឬ បែងចែកដាច់ដោយឡែកពីអង្គភាព និងលក់ ផ្ទេរផ្តល់អាជ្ញាបណ្ណជួល ឬដោះដូរគ្នាបានជាលក្ខណៈឯកត្តបុគ្គល ឬរួមគ្នាជាមួយកិច្ចសន្យាទាក់ទិន ទ្រព្យសកម្ម ឬ បំណុលអាចកំណត់បាន ដោយមិនគិតថាតើអង្គភាព មានបំណងធ្វើដូច្នេះ ឬ**

**(ខ)** **កើតចេញពីសិទ្ធិស្របច្បាប់និងតាមកិច្ចសន្យានានា ដោយមិន គិតថា សិទ្ធិទាំងនោះអាចផ្ទេរបាន ឬបំបែកចេញពីគ្នាបានពីអង្គភាព ឬពីទ្រព្យ និងកាតព្វកិច្ចទាំងនោះ ។**

## ការគ្រប់គ្រង

១៣ អង្គភាពមួយធ្វើការគ្រប់គ្រងលើទ្រព្យសកម្ម ប្រសិនបើអង្គភាពនោះមានអំណាចដើម្បីទាញយកផលប្រយោជន៍សេដ្ឋកិច្ចនា ពេលអនាគតដែលហូរចេញពីធនធានជាមូលដ្ឋាន ហើយមានអំណាចដើម្បីកម្រិតការប្រើប្រាស់នៃអង្គភាពផ្សេងទៀតចំពោះអត្ថប្រយោជន៍ទាំងនោះ ។ សមត្ថភាពរបស់អង្គភាពដើម្បីគ្រប់គ្រង ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីទ្រព្យសកម្មអរូបិយជាធម្មតានឹងមានប្រភពមកពីសិទ្ធិស្របច្បាប់ ដែលអាចអនុវត្ត បានតាមផ្លូវច្បាប់តុលាការ ។ នៅពេលដែលអវត្តមាននៃសិទ្ធិស្របច្បាប់វាមានការលំបាកច្រើន ដើម្បីបង្ហាញការគ្រប់គ្រង ។ ទោះជាយ៉ាងណាក៏ដោយ ការបង្ខំឱ្យអនុវត្តសិទ្ធិដោយច្បាប់ មិនមែនជាលក្ខខណ្ឌចាំបាច់សម្រាប់ការការគ្រប់គ្រងទេ ពីព្រោះអង្គភាពអាចមានលទ្ធភាពគ្រប់គ្រងលើផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតតាមមធ្យោបាយផ្សេងៗទៀតបាន ។

១៤ ចំណេះដឹងខាងបច្ចេកទេសនិងទីផ្សារ អាចផ្តល់នូវការកើតមានឡើងចំពោះផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត។ អង្គភាពត្រួតពិនិត្យផលប្រយោ-ជន៍ទាំងនោះ ជាឧទាហរណ៍ ប្រសិនបើចំណេះដឹងត្រូវបានការពារដោយសិទ្ធិស្របច្បាប់ ដូចជា សិទ្ធិថតចំលង ការរិតត្បិតចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្ម(ពេលមានការអនុញ្ញាត) ឬក៏តាមរយៈភារៈកិច្ចស្របច្បាប់ទៅលើនិយោជិកដើម្បីរក្សាកិច្ចការសម្ងាត់ ។

១៥ អង្គភាពមួយអាចមានក្រុមបុគ្គលិកដែលមានជំនាញ ហើយអាចកំណត់បាននូវជំនាញបន្ថែមរបស់គេ ដែលនាំឆ្ពោះទៅរកផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត តាមរយៈការបណ្តុះបណ្តាល ។ អង្គភាពអាចរំពឹងផងដែរថា

បុគ្គលិកនឹងបន្តធ្វើឱ្យជំនាញរបស់ពួកគេ ផ្តល់ប្រយោជន៍ដល់អង្គភាព។ ទោះបីជាយ៉ាងណាក៏ដោយ ជាធម្មតាអង្គភាពមានការគ្រប់គ្រងមិនគ្រប់គ្រាន់លើផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលបានរំពឹងទុកដែលកើតចេញពីបុគ្គលិកមួយក្រុមនិងពីការបណ្តុះបណ្តាលដើម្បីពិចារណាថាតើធាតុទាំងនេះបានបំពេញទៅតាមនិយមន័យរបស់ទ្រព្យសកម្មអរូបិយហើយឬនៅ ។ សម្រាប់ហេតុផលស្រដៀងគ្នានេះ ការគ្រប់គ្រងដ៏ជាក់លាក់ ឬក៏ទេពកោសល្យខាងបច្ចេទេស គឺទំនងជាមិនអាចបានបំពេញទៅតាម និយមន័យរបស់ទ្រព្យសកម្មអរូបិយទេ លើកលែងតែវាទទួលបានការការពារ ពីសិទ្ធិស្របច្បាប់ដើម្បីប្រើប្រាស់វា ហើយដើម្បីទទួលបាន នូវផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលបានរំពឹងទុក និងបានបំពេញផងដែរ នូវផ្នែកដទៃទៀតនៃនិយមន័យ ។

១៦ ដោយសារកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងទំនាក់ទំនងអតិថិជន និងភាពស្មោះត្រង់ជាមួយអតិថិជន អង្គភាពអាចមានអតិថិជនមួយក្រុម ឬក៏ចំណែកទីផ្សារដែលរំពឹងថាអតិថិជននឹងបន្តការជួញដូរជាមួយអង្គភាព ។ តែទោះជាយ៉ាងណា ក្នុងពេលអវត្តមាននៃសិទ្ធិស្របច្បាប់ដើម្បីការពារ ឬមធ្យោបាយត្រួតពិនិត្យផ្សេងទៀតទំនាក់ទំនងជាមួយអតិថិជនឬភាពស្មោះត្រង់របស់អតិថិជនចំពោះអង្គភាព ជាធម្មតាអង្គភាពមានប្រព័ន្ធគ្រប់គ្រងមិនគ្រប់គ្រាន់លើផលប្រយោជន៍សេដ្ឋកិច្ចពីទំនាក់ទំនង ជាមួយអតិថិជន និងភាពស្មោះត្រង់ ដើម្បីពិចារណាថា តើធាតុទាំងនោះ (ឧទាហរណ៍ អតិថិជនមួយក្រុម ចំណែកទីផ្សារទំនាក់ទំនងជាមួយអតិថិជន ភាពស្មោះត្រង់ចំពោះអតិថិជន ) អាចបំពេញទៅតាមនិយមន័យរបស់ទ្រព្យសកម្ម អរូបិយហើយឬនៅ ។ ក្នុងករណីដែលមិនមានសិទ្ធិស្របច្បាប់ ដើម្បីរក្សា

ការពារដល់ទំនាក់ទំនងជាមួយអតិថិជនរាល់ប្រតិបត្តិការដោះដូរគ្នាសម្រាប់ទំនាក់ទំនងអតិថិជនមិនមានកិច្ចសន្យាប្រហាក់ប្រហែលគ្នា ឬ ដូចគ្នា (ជាជាងជាផ្នែកមួយនៃការរួមបញ្ចូលអាជីវកម្មគ្នា) ផ្តល់ភស្តុតាងថា ទោះជាយ៉ាងក៏ដោយ អង្គភាពអាចគ្រប់គ្រងពីអត្ថប្រយោជនសេដ្ឋកិច្ច ដែលបានរំពឹងទុកដែលហូរពីទំនាក់ទំនងអតិថិជនទាំងនោះ។ ដោយសារតែប្រតិបត្តិ-ការដោះដូរបែបនេះក៏ផ្តល់នូវភស្តុតាងថា ទំនាក់ទំនងអតិថិជនអាចចែកដាច់ពីគ្នាទំនាក់ទំនងអតិថិជនទាំងនោះ អាចបំពេញទៅតាមនិយមន័យ នៃទ្រព្យសកម្មអរូបិយ ។

### អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត

១៧ អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលកើតចេញពីទ្រព្យសកម្មអរូបិយ អាចរួមបញ្ចូលនូវផលរបរពីការលក់ផលិតផល ឬសេវានានា ការសន្សំ សម្ចៃ ថ្លៃដើម ឬក៏ផលប្រយោជន៍ផ្សេងៗទៀត ដែលកើតចេញពីការប្រើប្រាស់ទ្រព្យសកម្មផ្សេងៗទៀតដោយអង្គភាព ។ ជាឧទាហរណ៍ ការប្រើប្រាស់កម្មសិទ្ធិបញ្ញា នៅក្នុងដំណើរការផលិតកម្មអាចកាត់បន្ថយថ្លៃដើមផលិតកម្មនាពេលអនាគតជាជាងការបង្កើនផលរបរនាពេលអនាគត ។

## ការទទួលស្គាល់និងការវាស់វែង

១៨ ការទទួលស្គាល់នៃធាតុមួយជាទ្រព្យសកម្មអរូបិយ តម្រូវឱ្យអង្គភាពមួយធ្វើការ បង្ហាញថា ធាតុនោះបំពេញទៅតាមៈ

ក. និយមន័យនៃទ្រព្យសកម្មអរូបិយ (សូមមើលកថាខណ្ឌ ៨-១៧) និង

ខ. លក្ខណៈវិនិច្ឆ័យលើការទទួលស្គាល់(សូមមើលកថាខណ្ឌទី២១-២៣)។

សេចក្តីតម្រូវនេះ អនុវត្តបានចំពោះថ្លៃដើមកើតឡើងដំបូង ដើម្បីទិញទ្រព្យសកម្មអរូបិយដែលបង្កើតឡើងផ្ទៃក្នុងនិងថ្លៃដើមដែលកើតឡើងបន្ទាប់ដើម្បីបូកបន្ថែម ជំនួសផ្នែក ឬផ្តល់សេវាកម្ម។

១៩ កថាខណ្ឌ ២៥-៣២ បកស្រាយអំពីការអនុវត្តលើលក្ខណៈវិនិច្ឆ័យទទួលស្គាល់ ចំពោះទ្រព្យសកម្មអរូបិយដែលបានទិញដាច់ដោយឡែកពីគ្នា និងកថាខណ្ឌ ៣៣-៤៣ បកស្រាយអំពីការអនុវត្តលើទ្រព្យសកម្មអរូបិយដែល បានមកពីការរួមអាជីវកម្មបញ្ចូលគ្នា ។ កថាខណ្ឌ ៤៤ បកស្រាយអំពីការ វាស់វែងលើកដំបូងនៃទ្រព្យសកម្មអរូបិយ ដែលផ្តល់ដោយជំនួយរដ្ឋាភិបាល កថាខណ្ឌ ៤៥-៤៧ ស្តីអំពីការការដោះដូរទ្រព្យសកម្មអរូបិយ និងកថាខណ្ឌ ៤៨-៥០ ស្តីអំពីការកំណត់មូលនិធិពាណិជ្ជកម្មដែលបង្កើតឡើងដោយអង្គ-ភាពផ្ទាល់ ។ កថាខណ្ឌ ៥១-៦៧ បកស្រាយអំពីការទទួលស្គាល់និងការ វាស់វែងគ្រាដំបូងពីទ្រព្យសកម្មអរូបិយដែលកើតឡើងដោយអង្គភាពផ្ទាល់ ។

២០ ក្នុងករណីជាច្រើន លក្ខណៈនៃទ្រព្យសកម្មអរូបិយ គឺថាមិនមានការបន្ថែមចំពោះទ្រព្យសកម្ម ឬការជំនួសនូវផ្នែកណាមួយទេ។ ដូចនេះការចំណាយជាបន្តបន្ទាប់ភាគច្រើនហាក់ដូចជាការរក្សាឱ្យអត្ថប្រយោជន៍សេដ្ឋកិច្ចដែលសង្ឃឹមនឹងទទួលបាននាពេលអនាគតឱ្យនៅដដែល ជាជាងបំពេញនិយម-ន័យនៃទ្រព្យសកម្មអរូបិយ និងលក្ខណៈវិនិច្ឆ័យទទួលស្គាល់នៅក្នុងស្តង់ដានេះ ។ បន្ថែមពីនេះទៀត ការចំណាយកើតឡើងជាបន្តបន្ទាប់មានការលំបាកក្នុងការបែងចែកផ្ទាល់ ទៅតាមទ្រព្យសកម្មអរូបិយជាក់លាក់ណា

មួយ ជាងការបែងចែកទៅ អាជីវកម្មទាំងមូល។ ដូច្នេះហើយ កម្រនឹងកើតមាន នៅចំណាយបន្តបន្ទាប់ ពេលគឺការចំណាយដែលបានកើតឡើងបន្ទាប់ ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មអរូបិយដែលបានទិញ ឬបន្ទាប់ពីការ បញ្ចប់នៃទ្រព្យសកម្មអរូបិយ ដែលទទួលបានផ្ទៃខាងក្នុងត្រូវបានគេទទួល ស្គាល់ជាតម្លៃយោងនៃទ្រព្យសកម្ម។ ស្របតាមកថាខណ្ឌ ៦៣ ការចំណាយ បន្តបន្ទាប់ទៅលើស្លាកសញ្ញាក្រុមហ៊ុន ឈ្មោះក្រុមហ៊ុន នៅក្នុងកាសែត កម្មសិទ្ធិបោះពុម្ពផ្សាយ បញ្ជីឈ្មោះអតិថិជន និងធាតុសំខាន់ៗ ប្រហាក់ ប្រហែលផ្សេងទៀត (ថាតើ ទិញពីខាងក្រៅ ឬទទួលបានផ្ទៃខាងក្នុង) តែងតែត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ-ខាត នៅពេល ដែលកើតមានឡើង ។ ពីព្រោះការចំណាយទាំងនេះ មិនខុសពីការចំណាយ សម្រាប់ការអភិវឌ្ឍអាជីវកម្មទាំងមូលឡើយ។

២១ ទ្រព្យសកម្មអរូបិយត្រូវបានទទួលស្គាល់ ប្រសិនបើៈ

**(ក) វាទំនងថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត អាចធ្វើឱ្យទ្រព្យសកម្មហូរចូលមកក្នុងអង្គភាព ។**

**(ខ) ថ្លៃដើមនៃទ្រព្យសកម្មអាចវាស់វែងបានយ៉ាងគួរឱ្យទុកចិត្តបាន ។**

**២២ អង្គភាពមួយត្រូវវាយតម្លៃពីភវនីយភាពនៃផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដោយប្រើប្រាស់ការសន្មតដែលអាចគាំទ្របាន និងសមហេតុផលដែល តំណាងឱ្យការប៉ាន់ស្មានដ៏ប្រសើរបំផុត របស់គណៈគ្រប់គ្រងពីលក្ខខណ្ឌសេដ្ឋកិច្ចដែលនឹងកើតមានលើអាយុកាលប្រើប្រាស់នៃទ្រព្យសកម្ម ។**

២៣ អង្គភាពមួយប្រើប្រាស់នូវការវិនិច្ឆ័យ ដើម្បីវាយតម្លៃកម្រិតនៃភាពប្រាកដប្រជាដោយភ្ជាប់ទៅនឹងលំហូរនៃផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលអាចបែងចែកដល់ការប្រើប្រាស់ទ្រព្យសកម្មដោយឈរលើមូលដ្ឋាន

នៃភស្តុតាងដែលអាចទទួលបាននៅពេលមានការទទួលស្គាល់លើកដំបូង ដោយផ្តល់ទំងន់ច្រើនទៅលើភស្តុតាងដែលមានប្រភពពីខាងក្រៅ ។

២៤ **ទ្រព្យសកម្មអរូបិយ ត្រូវបានធ្វើការវាស់វែងជាលើកដំបូងតាមថ្លៃដើម។**

### ការទិញចូលដាច់ដោយឡែក

២៥ ជាធម្មតា តម្លៃដែលអង្គភាពមួយចំណាយដើម្បីទិញទ្រព្យសកម្មអរូបិយដាច់ដោយឡែក ឆ្លុះបញ្ចាំងពីការរំពឹងទុកអំពីភវនីយភាពដែលអត្ថប្រយោជន៍សេដ្ឋកិច្ចនានា ដែលបានរំពឹងទុកនាពេលអនាគតដែលមាននៅក្នុងទ្រព្យសកម្មដែលនឹងហូរមកអង្គភាព ។ ម្យ៉ាងវិញទៀតអង្គភាពរំពឹងថានឹងមានលំហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ចទោះបីជាមានភាពមិនប្រាកដប្រជាអំពីពេលវេលា ឬចំនួនទឹកប្រាក់នៃលំហូរចូលក៏ដោយ ។ ហេតុនេះលក្ខណៈ វិនិច្ឆ័យនៃការទទួលស្គាល់ដែលមានភវនីយភាពនៅក្នុងកថាខណ្ឌ ២១ (ក) តែងតែត្រូវបានគេពិចារណានឹងត្រូវបំពេញសម្រាប់ទ្រព្យសកម្មអរូបិយបានទិញដាច់ដោយឡែក ។

២៦ លើសពីនេះទៅទៀត ថ្លៃដើមនៃទ្រព្យសកម្មអរូបិយបានទិញដាច់ដោយឡែកនោះ ជាធម្មតាអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បាន ។ នេះពិតជាមាន លក្ខណៈពិសេស នៅពេលដែលការតម្លៃតបស្នងនៃការទិញ ដែលធ្វើឡើង ក្នុងទម្រង់ជាសាច់ប្រាក់ ឬទ្រព្យសកម្មជារូបិយវត្ថុដទៃទៀត ។

២៧ ថ្លៃដើមនៃទ្រព្យសកម្មអរូបិយដែលបានទិញដាច់ដោយឡែក រួមមានៈ

(ក) តម្លៃទិញ រួមបញ្ចូលពន្ធនាំចូល ពន្ធលើការទិញមិនសងត្រឡប់វិញ បន្ទាប់ពីការដកចេញនូវអប្បហារពាណិជ្ជកម្ម និងប្រាក់បង្វិលមកវិញនិង

(ខ) ថ្លៃដើមចូលរួមដោយផ្ទាល់ណាមួយដើម្បីរៀបចំទ្រព្យសកម្មសម្រាប់គោលបំណងប្រើប្រាស់ ។

២៨ ឧទាហរណ៍ ថ្លៃដើមផ្ទាល់នៃទ្រព្យសកម្មអរូបិយ គឺៈ

(ក) ថ្លៃដើមនៃផលប្រយោជន៍និយោជិត (ដូចបានកំណត់នៅក្នុង ស.គ.អ.ក ១៩ ) ដែលកើតឡើងដោយផ្ទាល់ពីការ នាំទ្រព្យសកម្មចំពោះលក្ខខណ្ឌការងារ។

(ខ) ថ្លៃឈ្នួលវិជ្ជាជីវៈ ដែលកើតឡើងដោយផ្ទាល់ពីការនាំទ្រព្យសកម្មមកកាន់លក្ខខណ្ឌការងារ និង

(គ) ថ្លៃដើមនៃការធ្វើតេស្តថាតើទ្រព្យសកម្មនោះជាទ្រព្យសកម្មបំពេញមុខងារត្រឹមត្រូវដែរឬទេ ។

២៩ ឧទាហរណ៍ នៃការចំណាយដែលមិនមែនជាផ្នែកនៃថ្លៃដើមនៃទ្រព្យសកម្មអរូបិយ គឺៈ

(ក) ថ្លៃដើមនៃការដាក់ឱ្យប្រើប្រាស់ឬសេវាកម្មថ្មី(រួមបញ្ចូលថ្លៃផ្សាយពាណិជ្ជកម្ម និងសកម្មភាពលើកស្ទួយផលិតផល)

(ខ) ថ្លៃដើមនៃការដំណើរការអាជីវកម្មនៅក្នុងទីតាំងថ្មីឬជាមួយប្រភេទអតិថិជនថ្មី (រួមបញ្ចូលថ្លៃបណ្តុះបណ្តាលបុគ្គលិក) និង

(គ) ចំណាយរដ្ឋបាល និងចំណាយទូទៅផ្សេងៗទៀត ។

៣០ ការទទួលស្គាល់ថ្លៃដើមក្នុងតម្លៃយោងនៃទ្រព្យសកម្មអរូបិយត្រូវបានបញ្ឈប់ នៅពេលទ្រព្យសកម្មនោះ ស្ថិតនៅក្នុងលក្ខខណ្ឌចាំបាច់សម្រាប់

លទ្ធភាព នៃកិច្ចប្រតិបត្តិការអាជីវកម្មនៅក្នុងលក្ខណៈមួយ ដែលមានបំណងពី គណៈគ្រប់គ្រង ។ ហេតុដូច្នេះ ថ្លៃដើមដែលបានកើតដោយការប្រើប្រាស់ ឬការបង្ហាញឡើងវិញនូវទ្រព្យសកម្មអរូបិយ មិនត្រូវបានបញ្ចូលទៅក្នុងតម្លៃ យោងនៃទ្រព្យសកម្មនោះបានទេ ។ ឧទាហរណ៍ៈ ថ្លៃដើមខាងក្រោមនេះ មិនត្រូវបានរួមបញ្ចូលនៅក្នុងតម្លៃយោងនៃទ្រព្យសកម្មអរូបិយទេៈ

(ក) ថ្លៃដើមដែលកើតឡើងខណៈពេលដែលទ្រព្យសកម្មមានសមត្ថភាពប្រតិបត្តិការអាជីវកម្មនៅក្នុងលក្ខណៈមួយដែលមានបំណងពីអ្នកគ្រប់គ្រងដែលទ្រព្យអរូបិយនោះ មិនទាន់បាននាំយកមកប្រើប្រាស់នៅឡើយនិង

(ខ) ការខាតបង់ក្នុងកិច្ចប្រតិបត្តិការដំបូងដូចជាការខាតបង់ទាំងឡាយបានកើតឡើងខណៈពេលដែលមានតម្រូវការសម្រាប់ទិន្នផលនៃទ្រព្យសកម្មស្ថាបនាឡើង។

៣១ កិច្ចប្រតិបត្តិការខ្លះ កើតឡើងទាក់ទងជាមួយការអភិវឌ្ឍនៃទ្រព្យសកម្មអរូបិយ ប៉ុន្តែមិនចាំបាច់នាំទ្រព្យសកម្មនោះទៅកាន់លក្ខខណ្ឌចាំបាច់ ដើម្បីអាចធ្វើ កិច្ចប្រតិបត្តិការអាជីវកម្មបាន ដែលជាការចង់បានរបស់គណៈគ្រប់គ្រង ។ កិច្ចប្រតិបត្តិការចៃដន្យទាំងនោះ អាចកើតឡើងមុនពេល ឬក្នុងអំឡុងពេល ដែលមានសកម្មភាពអភិវឌ្ឍ ។ ដោយសារកិច្ចប្រតិបត្តិការដែលកើតឡើង ដោយចៃដន្យនោះមិនចាំបាច់ក្នុងការនាំទ្រព្យសកម្មទាំងនោះ ទៅកាន់ លក្ខខណ្ឌចាំបាច់ ដើម្បីអាចធ្វើកិច្ចប្រតិបត្តិការដែលជាការចង់បានរបស់ គណៈគ្រប់គ្រងឡើយ ចំណូលនិងចំណាយពាក់ព័ន្ធ នឹងកិច្ច

ប្រតិបត្តិការដែលកើតឡើងដោយចៃដន្យនោះ ត្រូវបានទទួលស្គាល់ភ្លាមៗ នៅក្នុង របាយការណ៍ចំណេញ ឬខាត និងបញ្ចូលក្នុងការចាត់ថ្នាក់នៃ ចំណូល និង ចំណាយរៀងគ្នា។

៣២ ប្រសិនបើ ការចំណាយសម្រាប់ទ្រព្យសកម្មអរូបិយត្រូវបានពន្យា លើសពីលក្ខខណ្ឌ ផ្ដល់ឥណទានធម្មតាថ្លៃដើមរបស់វា គឺជាថ្លៃដើមសមមូល សាច់ប្រាក់ ។ ភាពខុសគ្នារវាងទឹកប្រាក់នេះ និងការទូទាត់សរុប គឺត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់ លើរយៈពេលនៃឥណទាន លុះត្រាតែចំនួនទឹកប្រាក់នេះ ត្រូវបានធ្វើមូលធនកម្មដោយអនុលោមតាម ស.គ.អ.ក ២៣ *បន្ទុកលើប្រាក់កម្ចី* ។

## ការទិញផ្នែកមួយនៃការបញ្ចូលគ្នាអាជីវកម្មរួមគ្នា

៣៣ ដោយអនុលោមតាម ស.រ.ហ.អ.ក ៣ *ការបញ្ចូលអាជីវកម្មរួមគ្នា* ប្រសិនបើទ្រព្យសកម្មអរូបិយត្រូវបានទិញនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា ថ្លៃដើមនៃទ្រព្យសកម្មអរូបិយ គឺជាតម្លៃសមស្របនៅថ្ងៃទិញ ។ តម្លៃសមស្រប នៃទ្រព្យសកម្មអរូបិយ វាឆ្លុះបញ្ចាំងអំពីការរំពឹងទុកអំពីភវនីយភាពនៃផល ប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលហូរចូលមកក្នុងអង្គភាព ។ ម្យ៉ាង វិញទៀត អង្គភាពរំពឹងថានឹងមានការហូរចូលនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ទោះបីជាមានភាពមិនប្រាកដប្រជាអំពីពេលវេលា និងទឹកប្រាក់នៃលំហូរចូលក៏ដោយ ។ ដូច្នេះលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់ដែលមាន ភវនីយភាពនៅក្នុងកថាខណ្ឌ ២១ (ក) គឺតែងតែត្រូវបានចាត់ទុកថានឹងបំពេញឱ្យទ្រព្យសកម្មអរូបិយ ដែលបានទិញនៅក្នុងការបញ្ចូលអាជីវកម្ម បញ្ចូលគ្នា ។ ប្រសិនបើទ្រព្យសកម្មមួយដែលបានទិញនៅក្នុងការ

បញ្ចូល អាជីវកម្មរួមគ្នាអាចបំបែកចេញបាន ឬកើតចេញពីសិទ្ធិស្របច្បាប់ផ្សេង ទៀត ឬតាមកិច្ចសន្យា ព័ត៌មានគ្រប់គ្រាន់កើតឡើងដើម្បី វាស់វែងដោយ ជឿជាក់នូវតម្លៃសមស្របនៃទ្រព្យសកម្ម ។ ដូច្នេះ លក្ខខណ:វិនិច្ឆ័យការ វាស់វែងដ៏ជឿជាក់នៅក្នុងកថាខណ្ឌ ២១ (ខ) តែងតែត្រូវបានបានចាត់ ទុកថានឹងបំពេញឱ្យទ្រព្យសកម្មអរូបិយ ដែលបានទិញនៅក្នុងការបញ្ចូល អាជីវកម្មរួមគ្នា ។

៣៤ ដោយអនុលោមទៅតាមស្តង់ដា ស.រ.ហ.អ.ក ៣ (ដូចបានកែប្រែក្នុងឆ្នាំ ២០០៨) ដូច្នេះអ្នកទិញត្រូវទទួលស្គាល់នៅថ្ងៃទិញដាច់ដោយឡែកពី មូលនិធិពាណិជ្ជកម្មនូវទ្រព្យសកម្មអរូបិយរបស់របស់អ្នកលក់ ដោយមិនគិត ថាតើទ្រព្យសកម្មត្រូវបានទទួលស្គាល់ ដោយអ្នកលក់មុនការបញ្ចូលអាជីវ-កម្មរួមគ្នា ។ នេះមានន័យថា អ្នកទិញទទួលស្គាល់ជាទ្រព្យសកម្មដាច់ដោយឡែក មូលនិធិពាណិជ្ជកម្មនូវគម្រោងស្រាវជ្រាវនិងអភិវឌ្ឍស្ថិតក្នុងដំណើរការ ប្រសិនបើគម្រោងបំពេញនិយមន័យនៃទ្រព្យសកម្មអរូបិយ។ គម្រោងស្រាវជ្រាវនិងអភិវឌ្ឍស្ថិតក្នុងដំណើរការបំពេញនិយមន័យនៃទ្រព្យសកម្មអរូបិយ នៅពេលវា:

(ក) បំពេញនិយមន័យនៃទ្រព្យសកម្ម និង

(ខ) អាចកំណត់បានពោល គឺអាចបំបែកចេញពីគ្នាបាន ឬកើតចេញពីសិទ្ធស្របច្បាប់ឬកិច្ចសន្យាដទៃទៀត ។

## ការវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្មអរូបិយដែលបានទិញ នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា

៣៥ តម្លៃសមស្របនៃទ្រព្យសកម្មអរូបិយ ដែលបានទិញនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាអាចបំបែកពីគ្នាបានឬកើតឡើងពីសិទ្ធិស្របច្បាប់ឬតាមកិច្ចសន្យាផ្សេងទៀត ព័ត៌មានគ្រប់គ្រាន់កើតឡើងដើម្បីវាស់វែងដោយជឿជាក់នូវតម្លៃសមស្របនៃទ្រព្យសកម្ម ។ សម្រាប់ការប៉ាន់ស្មានដែលបានប្រើដើម្បីវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្មអរូបិយនៅពេលមានចន្លោះនៃលទ្ធផលដែលអាចកើតឡើងបានជាមួយភវនីយភាពខុសគ្នាៗ ភាពមិនប្រាកដប្រជា នោះបញ្ចូលទៅក្នុងការវាស់វែងនៃតម្លៃសមស្រប ។

៣៦ ទ្រព្យសកម្មអរូបិយដែលបានទិញ នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាអាចមានលក្ខណៈដាច់ដោយឡែកប៉ុន្តែជាមួយនឹងកិច្ចសន្យាទាក់ទិនតែប៉ុណ្ណោះទ្រព្យសកម្ម ឬបំណុលដែលអាចកំណត់បាន ។ នៅក្នុងករណីបែបនេះ អ្នកទិញទទួលស្គាល់ទ្រព្យសកម្មអរូបិយដាច់ដោយឡែកពីមូលនិធិពាណិជ្ជកម្មប៉ុន្តែរួមជាមួយនឹងធាតុទាក់ទិន ។

៣៧ អ្នកទិញអាចទទួលស្គាល់ក្រុមនៃទ្រព្យសកម្មអរូបិយបន្ថែមជាទ្រព្យសកម្មតែមួយបានដោយដឹងថា ទ្រព្យសកម្មនីមួយៗមានអាយុកាលស្រដៀងគ្នា។ ឧទាហរណ៍ ពាក្យ “ស្លាកសញ្ញា” និង “ស្លាកឈ្មោះ” ជារឿយៗ ត្រូវបានប្រើជាពាក្យដែលមានន័យតែមួយសម្រាប់ស្លាកសញ្ញាពាណិជ្ជកម្ម និងស្លាកសញ្ញាផ្សេងទៀត ។ ប៉ុន្តែពាក្យមិនគឺជាពាក្យផ្សាយជាទូទៅដែលត្រូវបានប្រើយ៉ាងច្រើនដើម្បីសម្តៅដល់ក្រុមនៃទ្រព្យសកម្មបន្ថែមដូចជាស្លាកសញ្ញាពាណិជ្ជកម្ម (ឬ ស្លាកសញ្ញាសេវា) និងពាក្យពាណិជ្ជកម្មទាក់ទិន រូបមន្តបញ្ជីមុខម្ហូប និង ជំនាញបច្ចេកវិជ្ជា ។

៣៨ [លុបចោល]

៣៩ តម្លៃទីផ្សារដែលបានស្រង់នៅក្នុងទីផ្សារសកម្មមួយ ផ្តល់នូវការប៉ាន់ស្មានយ៉ាងគួរឱ្យជឿជាក់បានបំផុតនូវតម្លៃទីផ្សារនៃទ្រព្យអរូបិយ ( សូមមើលកថាខណ្ឌ ៧៨ )។ តម្លៃទីផ្សារសមស្រប គឺជាតម្លៃដេញថ្លៃបច្ចុប្បន្ន។ ប្រសិនបើគ្មានតម្លៃដេញថ្លៃបច្ចុប្បន្នទេ ថ្លៃនៃប្រតិបត្តិការស្រដៀងគ្នា នាពេលថ្មីៗអាចផ្តល់នូវមូលដ្ឋាន ដើម្បីប៉ាន់ស្មានតម្លៃសមស្របបានប្រសិនបើគ្មានការផ្លាស់ប្តូរធំៗ ក្នុងកាលៈទេសៈសេដ្ឋកិច្ចរវាងកាលបរិច្ឆេទ នៃប្រតិបត្តិការនិងកាលបរិច្ឆេទដែលតម្លៃសមស្របនៃទ្រព្យសកម្មត្រូវបានគេប៉ាន់ស្មាន ។

៤០ ប្រសិនបើគ្មានទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មកើតមានទេនោះ តម្លៃសមស្របរបស់វាគឺជាទឹកប្រាក់ដែលអង្គភាពត្រូវបង់សម្រាប់ទ្រព្យសកម្មនោះនៅថ្ងៃទិញ នៅក្នុងប្រតិបត្តិការទិញដូរ រវាងភាគីដែលមានចំណេះដឹង និងឆន្ទៈ ដោយផ្អែកលើព័ត៌មានដ៏ប្រសើរបំផុតដែលមាន។ នៅក្នុងការ កំណត់ចំនួនទឹកប្រាក់នេះ អង្គភាពត្រូវពិចារណាលើលទ្ធផលនៃប្រតិបត្តិការថ្មីៗសម្រាប់ទ្រព្យសកម្មដែលស្រដៀងគ្នា ។ ឧទាហរណ៍ អង្គភាព មួយអាចប្រើមេគុណ ដែលឆ្លុះបញ្ចាំងពីប្រតិបត្តិការទីផ្សារបច្ចុប្បន្នទឹកត្តា ទាំងឡាយដែលនាំមកនូវលទ្ធភាពចំណេញនៃទ្រព្យសកម្ម (ដូចជា ចំណូល ផលចំណេញប្រតិបត្តិការ ឬចំណេញមុនពេលបង់ការប្រាក់មុនពេល បង់ពន្ធរំលស់ )

៤១ អង្គភាព ដែលពាក់ព័ន្ធនៅក្នុងប្រតិបត្តិការទិញនិងលក់ទ្រព្យអរូបិយអាចបង្កើតបច្ចេកទេសសម្រាប់ការប៉ាន់ស្មានតម្លៃសមស្របដោយប្រយោល។ បច្ចេកទេសទាំងនេះអាចត្រូវបានប្រើប្រាស់ជាដំបូងសម្រាប់វាស់វែងទ្រព្យ

អរូបិយដែលបានទិញនៅក្នុងការរួមអាជីវកម្មបញ្ចូលគ្នាប្រសិនបើគោលបំណងរបស់គេដើម្បីប៉ាន់ស្មាន តម្លៃសមស្រប និងប្រសិនបើពួកគេឆ្លុះបញ្ចាំង អំពីប្រតិបត្តិការបច្ចុប្បន្ន និងការអនុវត្តនៅក្នុងឧស្សាហកម្ម ដែលទ្រព្យ សកម្មដែលជាកម្មសិទ្ធិរបស់គេ ។ បច្ចេកទេសទាំងនេះ រួមមានឧទាហរណ៍ៈ

ក. ធ្វើអប្បហារពីលំហូរសាច់ប្រាក់ពិតប៉ាន់ស្មាននាពេលអនាគត ពីទ្រព្យសកម្ម

ខ. ធ្វើការប៉ាន់ស្មានថ្លៃដើមដែលអង្គភាពជៀសវាងដោយការកាន់កាប់ទ្រព្យសកម្មអរូបិយនិងមិនចាំបាច់ៈ

(១) ដើម្បីធ្វើអាជ្ញាបណ្ណពីភាគីផ្សេងទៀតនៅក្នុងប្រតិបត្តិការធម្មតា (ដូចមាននៅក្នុងវិធីសាស្ត្រ“ដកចេញពីសួយសារ” ដោយប្រើសាច់ប្រាក់ពិតដែលបានធ្វើអប្បហាររួច) ឬ

(២) ដើម្បីបង្កើតឡើងវិញ ឬជំនួសវាវិញ (ដូចមាននៅក្នុងវិធីសាស្ត្រថ្លៃដើម)

**ការចំណាយបន្តបន្ទាប់លើគម្រោងដំណើរការស្រាវជ្រាវ និងការអភិវឌ្ឍន៍កំពុងដំណើរការ**

**៤២ ចំណាយស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលៈ**

ក. ជាប់ទាក់ទងទៅនឹងគម្រោងស្រាវជ្រាវ ឬការអភិវឌ្ឍកំពុងដំណើរការដែលបានទិញដាច់ដោយឡែក ឬនៅក្នុងការបញ្ចូល អាជីវកម្មរួមគ្នា និងត្រូវបានទទួលស្គាល់ជាទ្រព្យអរូបិយ និង

**ខ. កើតឡើងក្រោយពេលដែលការទិញនៃគម្រោងនោះនឹងត្រូវបាន ធ្វើគណនេយ្យកម្មតាមកថាខណ្ឌ៥៤-៦២។**

៤៣ ដោយអនុវត្តការតម្រូវ នៅក្នុងកថាខណ្ឌ ៥៤-៦២ មានន័យថា ចំណាយជាបន្តបន្ទាប់ ចំពោះគម្រោងស្រាវជ្រាវ ឬអភិវឌ្ឍន៍កំពុងដំណើរការ ដែលទទួលបានដាច់ដោយឡែកឬនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា និងត្រូវទទួលស្គាល់ជាទ្រព្យអរូបិយគឺៈ

(ក) ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលកើតឡើង ប្រសិនបើវាជាចំណាយការស្រាវជ្រាវ។

(ខ) ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលកើតឡើង ប្រសិនបើចំណាយអភិវឌ្ឍដែលមិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់ ជាទ្រព្យអរូបិយនៅក្នុងកថាខណ្ឌ ៥៧ និង

(គ) ត្រូវបានបន្ថែមទៅក្នុងតម្លៃយោងនៃគម្រោងស្រាវជ្រាវនិងអភិវឌ្ឍ ប្រសិនបើការចំណាយអភិវឌ្ឍន៍គម្រោង ប្រសិនបើមានការចំណាយលើការអភិវឌ្ឍដែលបំពេញឱ្យលក្ខណៈវិនិច្ឆ័យសម្រាប់ការ ទទួលស្គាល់នៅក្នុងកថាខណ្ឌ ៥៧ ។

**ការទិញដោយអំណោយពីរដ្ឋាភិបាល**

៤៤ ក្នុងករណីខ្លះ ទ្រព្យសកម្មអរូបិយអាចទទួលបានដោយមិនអស់ប្រាក់ ឬក៏តម្លៃតបស្នងតិចតួចតាមរយៈអំណោយពីរដ្ឋាភិបាល ។ ករណីនេះ អាចកើតមានឡើងនៅពេលដែលរដ្ឋាភិបាលបានផ្ទេរ ឬក៏បែងចែកទ្រព្យសកម្មអរូបិយ ទៅឱ្យអង្គភាពមួយ ដូចជាសិទ្ធិចុះចតនៅអាកាសយានដ្ឋាន អាជ្ញា-ប័ណ្ណ ដើម្បីធ្វើអាជីវកម្មលើស្ថានីយ៍ទូរទស្សន៍ និងវិទ្យុ អាជ្ញាប័ណ្ណនាំចូល

ឬ កូតា ឬក៏សិទ្ធិដើម្បីប្រើប្រាស់ធនធានផ្សេងៗទៀតដែលមានការដាក់កម្រិត ។ អនុលោមទៅតាម ស.គ.អ.ក ២០ *គណនេយ្យសម្រាប់អំណោយពីរដ្ឋាភិបាល និងការលាតត្រដាងបង្ហាញពីជំនួយដោយរដ្ឋាភិបាល* អង្គភាពមួយអាចជ្រើសរើសទទួលស្គាល់ទ្រព្យសកម្មអរូបិយ និងអំណោយដំបូងជាតម្លៃសមស្រប ។ ប្រសិនបើអង្គភាពនោះ ជ្រើសរើសមិនទទួលស្គាល់ទ្រព្យសកម្មជាលើកដំបូងតម្លៃសមស្របទេនោះ អង្គភាពត្រូវទទួលស្គាល់ទ្រព្យសកម្មជាដំបូងតាមទឹកប្រាក់បន្តិចបន្តួច ( ការទទួលស្គាល់ផ្សេងទៀតត្រូវបានអនុញ្ញាតដោយ ស.គ.អ.ក ២០ ) បូកជាមួយការចំណាយខ្លះៗ ដែលអាចផ្តល់ដោយផ្ទាល់ដល់ការរៀបចំទ្រព្យសកម្មសម្រាប់ការប្រើប្រាស់ប្រកបដោយចេតនារបស់ខ្លួន។

**ការដោះដូរទ្រព្យសកម្ម**

៤៥ ទ្រព្យសកម្មអរូបិយមួយ ឬច្រើនអាចត្រូវបានទិញជាការដោះប្តូរសម្រាប់ទ្រព្យ សកម្មមិនមែនរូបិយវត្ថុ ឬទ្រព្យសកម្ម ឬការបញ្ចូលគ្នានៃទ្រព្យសកម្មទាំងពី ។ ការពិភាក្សាខាងក្រោម យោងទៅលើការការដោះដូរទ្រព្យ មិនមែនរូបិយវត្ថុជាមួយទ្រព្យមិនមែនរូបិយវត្ថុមួយផ្សេងទៀត ប៉ុន្តែគេក៏ អនុវត្តចំពោះការផ្លាស់ប្តូរទាំងអស់ ដូចដែលបានពណ៌នានៅប្រយោគខាង ដើម ។ ថ្លៃដើមនៃទ្រព្យសកម្មអរូបិយនេះ ត្រូវបានវាស់វែងនៅតម្លៃសមស្របលុះត្រាតែ (ក) ការដោះដូរខ្វះលក្ខណៈ ពាណិជ្ជកម្ម ឬ (ខ)តម្លៃសមស្របមិនមែនទ្រព្យសកម្មដែលបានទទួល និងមិនមែនទ្រព្យសកម្មបោះបង់ចោល ដែលអាចបានវាស់វែងគួរឱ្យទុកចិត្តទេ។ ទ្រព្យសកម្មដែលបានទិញត្រូវបានគេវាស់វែងតាមមធ្យោបាយនេះ ទោះបីជាអង្គភាពមិនអាចមិនឈប់ទទួលស្គាល់ភ្លាមៗ នូវទ្រព្យសកម្មដែលបានការបោះបង់ចោល ក៏

ដោយ ។ ប្រសិនបើ ទ្រព្យសកម្មដែលបានទិញមិនអាចវាស់វែងតាម តម្លៃសមស្របបានទេនោះ ថ្លៃដើមរបស់ត្រូវបានវាស់វែងតាមតម្លៃយោង នៃទ្រព្យសកម្មដែលបោះបង់ចោលវិញ ។

៤៦ អង្គភាពមួយកំណត់ថាតើ ការប្រតិបត្តិការដោះដូរមួយ មានលក្ខណៈ ជាពាណិជ្ជកម្ម ដោយការពិចារណាលើទំហំចំពោះលំហូរសាច់ប្រាក់នៅ ពេលអនាគត ត្រូវបានគេរំពឹងទុកថានឹងប្រែប្រួល ដែលជាលទ្ធផលនៃ ប្រតិបត្តិការ ។ ប្រតិបត្តិការដោះដូរដែលមានលក្ខណៈពាណិជ្ជកម្ម ប្រសិនបើៈ

(ក) រូបសណ្ឋាន (ឧទាហរណ៍ ហានិភ័យ ពេលវេលា និងទឹកប្រាក់) នៃលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានទទួលខុសពីរូបសណ្ឋានលំហូរសាច់ប្រាក់ នៃទ្រព្យសកម្មដែលបានផ្ទេរ ឬ

(ខ) តម្លៃជាក់លាក់របស់អង្គភាពនៃផ្នែកមួយនៃកិច្ចប្រតិបត្តិការ របស់អង្គភាព ដែលបានប៉ះពាល់ដោយការប្រតិបត្តិការដោះដូរ ជាលទ្ធផលនៃការដោះដូរនោះ និង

(គ) ភាពខុសគ្នានៅក្នុង (ក) ឬ (ខ) គឺមានសំខាន់ ដែលជាប់ ទាក់ទងទៅនឹងតម្លៃសមស្របនៃទ្រព្យសកម្មដែលបានដោះដូរ។

ក្នុងគោលបំណងនៃការកំណត់ថាតើ ប្រតិបត្តិការដោះដូរ មានលក្ខណៈ ជាពាណិជ្ជកម្មឬយ៉ាងណានោះ តម្លៃជាក់លាក់របស់អង្គភាព នៃផ្នែកមួយ នៃកិច្ចប្រតិបត្តិការរបស់អង្គភាព ត្រូវប៉ះពាល់ដល់លំហូរសាច់ប្រាក់ ក្រោយការបង់ពន្ធ ។ លទ្ធផលនៃការវិភាគនេះអាចមានភាពច្បាស់លាស់ ដោយគ្មានអង្គភាពណាមួយ ត្រូវអនុវត្តការគណនាលម្អិតនោះទេ ។

៤៧ កថាខណ្ឌ ២១(ខ) បញ្ជាក់ថាលក្ខខណ្ឌសម្រាប់ទទួលស្គាល់នៃទ្រព្យ-សកម្មអរូបិយគឺថាថ្លៃដើមនៃទ្រព្យសកម្មអរូបិយអាចវាស់វែងគួរឱ្យទុកចិត្ត

បាន។ តម្លៃសមស្របនៃទ្រព្យអរូបិយសម្រាប់ប្រតិបត្តិការទីផ្សារដែលមានការប្រៀបធៀបមិនកើតមានត្រូវបានវាស់វែង ដែលគួរឱ្យជឿទុកចិត្តបានប្រសិនបើ (ក)នៅពេលមានការប្រែប្រួលនៅក្នុងចន្លោះនៃការប៉ាន់ស្មានតម្លៃសមស្របមិនសូវសំខាន់សម្រាប់ទ្រព្យសកម្មនោះឬ (ខ)ភវនីយភាពនៃការប៉ាន់ស្មានផ្សេងៗនៅក្នុងចន្លោះអាចធ្វើការវាយតម្លៃគួរឱ្យទទួលយកបាននិងត្រូវបានប្រើប្រាស់នៅក្នុងការប៉ាន់ស្មានអំពីតម្លៃសមស្រប។ ប្រសិនបើអង្គភាពអាចកំណត់តម្លៃសមស្របដែលគួរឱ្យទទួល យកបានទាំងទ្រព្យសកម្មដែលបានទទួលឬទ្រព្យសកម្មដែលត្រូវគេបោះ បង់ចោលនៅពេលនោះ តម្លៃសមស្របនៃទ្រព្យសកម្មដែលគេបោះបង់ ចោលត្រូវបានប្រើប្រាស់ដើម្បីវាស់វែងថ្លៃដើមលុះត្រាតែតម្លៃសមស្របនៃទ្រព្យសកម្មដែលបានទទួលច្រើនជាង និងច្បាស់លាស់ជាង ។

**មូលនិធិពាណិជ្ជកម្មដែលបង្កើតពីផ្ទៃខាងក្នុង**

៤៨ **មូលនិធិពាណិជ្ជកម្មដែលកើតពីផ្ទៃក្នុង មិនត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មទេ។**

៤៩ នៅក្នុងករណីខ្លះ ការចំណាយបានកើតមានឡើង ដើម្បីបង្កើតផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត តែវាមិនផ្តល់ការបង្កើតឡើងនៃទ្រព្យសកម្មអរូបិយ ដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យការទទួលស្គាល់ក្នុងស្តង់ដានេះទេ។ ការចំណាយបែបនេះ ជាញឹកញាប់ត្រូវបានពិពណ៌នាថាជ ការចូលរួមបង្កើតមូលនិធិពាណិជ្ជកម្មដែលបង្កើតឡើងពីផ្ទៃខាងក្នុង។ មូលនិធិពាណិជ្ជកម្មដែលបង្កើតឡើងពីផ្ទៃខាងក្នុង មិនត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មទេ ពីព្រោះវាមិនមែនជាធនធានមួយអាចកំណត់បាន (វាមិនអាចបំបែកចេញបានថែមទាំងវាមិនកើតឡើងពីសិទ្ធិស្របច្បាប់ឬតាមកិច្ច-

សន្យា) ដែលគ្រប់គ្រងដោយអង្គភាព ដែលមិនអាចវាស់វែងថ្លៃដើមគួរឱ្យទុកចិត្តបាន។

៥០ ភាពខុសគ្នារវាងតម្លៃសមស្របរបស់អង្គភាពមួយ និងតម្លៃយោងនៃ ទ្រព្យសកម្មពិតដែលអាចកំណត់បាន អាចចាប់បាននូវចន្លោះនៃកត្តាដែល ជះឥទ្ធិពលដល់តម្លៃអង្គភាព ។ ទោះជាយ៉ាងណាភាពខុសគ្នានោះមិនតំណាងឱ្យថ្លៃដើមនៃទ្រព្យសកម្មអរូបិយ ដែលបានគ្រប់គ្រងដោយអង្គភាពបានទេ ។

## ទ្រព្យសកម្មអរូបិយដែលបង្កើតពីផ្ទៃខាងក្នុង

៥១ ជួនកាលមានការពិបាកដើម្បីវាយតម្លៃថា តើទ្រព្យសសកម្មអរូបិយដែលបង្កើតឡើងពីផ្ទៃក្នុងមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ការទទួលស្គាល់ដែរឬអត់ ។ ដោយសារបញ្ហានៅក្នុង:

(ក) ការកំណត់ថាតើ និងពេលណាដែលមានទ្រព្យសកម្មដែលអាចកំណត់បាន ដែលនឹងទំនងជាបង្កើតបាននូវផលប្រយោជន៍ សេដ្ឋកិច្ចនាពេលអនាគត?

(ខ) ការកំណត់ថ្លៃដើមនៃទ្រព្យសកម្មដោយគួរឱ្យទុកចិត្តបាន ។ ក្នុងករណីខ្លះថ្លៃដើម នៃការបង្កើតទ្រព្យសកម្មអរូបិយផ្ទៃខាងក្នុងមិនអាចញែកចេញដាច់ពីថ្លៃដើមនៃការរក្សាឬក៏ការបង្កើនមូលនិធិពាណិជ្ជកម្ម ដែលកើតពីផ្ទៃខាងក្នុងរបស់អង្គភាពឬក៏ការធ្វើកិច្ចការ អាជីវកម្មពីមួយថ្ងៃទៅមួយថ្ងៃ ។

ដូច្នេះ បន្ថែមលើការអនុលោមទៅតាមសេចក្ដីតម្រូវ ជាទូទៅចំពោះការទទួលស្គាល់ និងការវាស់វែងជាបឋមនៃទ្រព្យសកម្មអរូបិយ អង្គភាពអនុវត្តតាមការតម្រូវ និងគោលការណ៍ណែនាំក្នុងកថាខណ្ឌ៥២-៦៧ខាងក្រោមនេះ ចំពោះរាល់ទ្រព្យសកម្មអរូបិយដែលបង្កើតបានពីផ្ទៃខាងក្នុងទាំងអស់ ។

៥២ ដើម្បីវាយតម្លៃថា តើទ្រព្យសកម្មអរូបិយដែលបង្កើតបានពីខាងក្នុងការបំពេញទៅតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ដែរ ឬទេនោះអង្គភាពត្រូវចាត់ថ្នាក់ការបង្កើតឡើងនៃទ្រព្យសកម្មជាៈ

(ក) ដំណាក់កាលការស្រាវជ្រាវ និង

(ខ) ដំណាក់កាលការអភិវឌ្ឍ ។

ទោះបីជាវាក្យស័ព្ទ "ស្រាវជ្រាវ" និង "ការអភិវឌ្ឍ" ត្រូវបានកំណត់ និយមន័យ (ចំពោះវាក្យស័ព្ទ "ដំណាក់កាលការស្រាវជ្រាវ"និង "ដំណាក់ កាលការអភិវឌ្ឍន៍" យ៉ាងទូលាយសម្រាប់គោលបំណង នៃស្តង់ដានេះទៅទៀត ។

៥៣ ប្រសិនបើអង្គភាពមិនអាចញែកចេញឱ្យដាច់ពីគ្នា រវាងដំណាក់កាលការស្រាវជ្រាវពីដំណាក់កាលការអភិវឌ្ឍរបស់គម្រោងផ្ទៃក្នុង ដើម្បីបង្កើតទ្រព្យសកម្មអរូបិយទេ អង្គភាពនឹងចាត់ទុកការចំណាយលើគម្រោងនោះ ថាជាការកើតមានតែក្នុងដំណាក់កាលការស្រាវជ្រាវប៉ុណ្ណោះ ។

**ដំណាក់កាលស្រាវជ្រាវ**

**៥៤ មិនមានទ្រព្យសកម្មអរូបិយដែលកើតចេញពីការស្រាវជ្រាវ (ដំណាក់កាលនៃការស្រាវជ្រាវនៃគម្រោងផ្ទៃក្នុង)ត្រូវបានទទួលស្គាល់ឡើយ ។ ការ**

**ចំណាយលើការស្រាវជ្រាវ (ឬដំណាក់កាលការស្រាវជ្រាវនៃគម្រោងផ្ទៃក្នុង) ត្រូវបាន ទទួលស្គាល់ថា ជាការចំណាយនៅពេលវាកើតឡើង ។**

៥៥ នៅក្នុងដំណាក់កាលការស្រាវជ្រាវនៃគម្រោងផ្ទៃក្នុង អង្គភាពមួយមិនអាចបង្ហាញថា ទ្រព្យសកម្មអរូបិយដែលកើតមានដែលនឹងទំនងជាបង្កើតឱ្យមានផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតឡើយ ។ ហេតុដូច្នេះការចំណាយនេះ ត្រូវបានទទួលស្គាល់ថា ជាចំណាយនៅពេលវាកើតឡើង ។

៥៦ ឧទាហរណ៍នៃសកម្មភាពស្រាវជ្រាវមានៈ

(ក) សកម្មភាពមានគោលដៅ ដើម្បីទទួលយកចំណេះដឹងថ្មីបន្ថែម

(ខ) ការស្រាវជ្រាវការវាយតម្លៃ និងការជ្រើសរើសចុងក្រោយនៃការអនុវត្តការស្រាវជ្រាវស្វែងរក ឬក៏ចំណេះដឹងថ្មីៗ ។

(គ) ការស្រាវជ្រាវរកជម្រើសសម្រាប់សម្ភារៈគ្រឿងបរិក្ខា ផលិតផលដំណើរការប្រព័ន្ធ ឬសេវានានា

(ឃ) ការបង្កើតឡើង ការរចនាប្លង់ ការវាយតម្លៃ និងការជ្រើសរើសចុងក្រោយនៃជម្រើសដែលអាចធ្វើទៅបានចំពោះការសម្ភារៈល្អៗ ឧបករណ៍ ផលិតផល ដំណើរការប្រព័ន្ធ ឬសេវានានា ។

## ដំណាក់កាលអភិវឌ្ឍន៍

**៥៧ ទ្រព្យសកម្មអរូបិយដែលកើតចេញពីការអភិវឌ្ឍ (ឬដំណាក់កាលការអភិវឌ្ឍនៃគម្រោងខាងក្នុង) ត្រូវបានទទួលស្គាល់ ប្រសិនបើ និងតែប្រសិនបើ អង្គភាពអាចបង្ហាញជូនកត្តាទាំងអស់ដូចខាង ក្រោមៈ**

(ក) លទ្ធភាពដែលអាចធ្វើទៅបានខាងបច្ចេកទេស ក្នុងការបញ្ចប់ ទ្រព្យសកម្មអរូបិយដូច្នេះហើយវា នឹងមានសម្រាប់ការប្រើប្រាស់ឬលក់បាន។

(ខ) ចេតនារបស់ខ្លួនក្នុងការបញ្ចប់ទ្រព្យសកម្មអរូបិយ និងដើម្បីប្រើប្រាស់ ឬក៏លក់វា ។

(គ) លទ្ធភាពរបស់ខ្លួនដើម្បីប្រើប្រាស់ ឬ លក់ទ្រព្យសកម្មអរូបិយ ។

(ឃ) របៀបដែលទ្រព្យសកម្មអរូបិយ ដែលទំនងជានឹងបង្កើតផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ។ ក្នុងចំណោមចំណុចផ្សេងៗទៀតអង្គភាពអាចបង្ហាញពីការកើតមានឡើងនៃទីផ្សារសម្រាប់ទិន្នផលនៃទ្រព្យសកម្មអរូបិយ ឬទ្រព្យសកម្ម អរូបិយខ្លួនឯង ឬប្រសិនបើវាសម្រាប់តែការប្រើប្រាស់ផ្ទៃក្នុង ឬក៏ សារៈប្រយោជន៍របស់ទ្រព្យសកម្មអរូបិយ ។

(ង) ភាពដែលអាចរកបាននៃបច្ចេកទេសហិរញ្ញវត្ថុ និងធនធាន ផ្សេងៗទៀតដែលគ្រប់គ្រាន់ ដើម្បីបញ្ចប់ការអភិវឌ្ឍ និងដើម្បីប្រើប្រាស់ឬលក់ទ្រព្យសកម្មអរូបិយនោះ ។

(ច) លទ្ធភាពរបស់វា ដើម្បីវាស់វែងការចំណាយដែលអាចផ្តល់ដល់ទ្រព្យសកម្មអរូបិយ ក្នុងអំឡុងពេល នៃការអភិវឌ្ឍរបស់វាយ៉ាងគួរឱ្យ ទុកចិត្តបាន ។

៥៨ ក្នុងដំណាក់កាលការអភិវឌ្ឍគម្រោងផ្ទៃក្នុងនៅក្នុងករណីខ្លះ អង្គភាពមួយកំណត់ទ្រព្យសកម្មអរូបិយ និងបង្ហាញឱ្យឃើញថា ទ្រព្យសកម្មទំនងជានឹងបង្កើតផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ។ នេះក៏ព្រោះតែដំណាក់កាល អភិវឌ្ឍគម្រោងរីកចម្រើន ជាងដំណាក់កាលការស្រាវជ្រាវ ។

៥៩ ឧទាហរណ៍នៃសកម្មភាពការអភិវឌ្ឍមានដូចជាៈ

(ក) ការរចនាប្លង់ ការសាងសង់ ការធ្វើតេស្តមុនផលិតកម្ម ឬ គំរូដើម មុនពេលប្រើប្រាស់ និង ម៉ូឌែល ។

(ខ) ការរចនាឧបករណ៍ ពុម្ព និងកូនឡុកឡាក់ ដែលពាក់ព័ន្ធនឹងបច្ចេកវិជ្ជាទំនើប ។

(គ) ការរចនាប្លង់ ការសាងសង់ និងកិច្ចប្រតិបត្តិការនៃរោងចក្រគំរូ ដែលមិនមែនជាមាត្រដ្ឋាន សេដ្ឋកិច្ចមួយដែលអាចធ្វើទៅបាន ចំពោះផលិតកម្មពាណិជកម្ម និង

(ឃ) ការរចនាប្លង់ ការសាងសង់ និងការធ្វើតេស្តរកជម្រើសថ្មី ឬ បានធ្វើឱ្យប្រសើរឡើងនូវ សម្ភារៈ គ្រឿងបរិក្ខា ផលិតផលដំណើរការ ប្រព័ន្ធ ឬ សេវានានា។

៦០ ដើម្បីបង្ហាញពីរបៀបដែលទ្រព្យសកម្មអរូបិយនឹងបង្កើតផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលទំនងជាកើតមានឡើង អង្គភាពវាយតម្លៃពីអត្ថប្រយោជន៍សេដ្ឋកិច្ចដែលនឹងត្រូវទទួលបានពីទ្រព្យសកម្មអរូបិយដោយឈរលើមូលដ្ឋាន ស.គ.អ.ក ៣៦ *ការធ្លាក់ចុះតម្លៃនៃទ្រព្យសកម្ម* ។ ប្រសិនបើទ្រព្យសកម្មមានផលប្រយោជន៍ខាងសេដ្ឋកិច្ច តែនៅក្នុងការបញ្ចូលទ្រព្យសកម្មជាមួយគ្នានោះ អង្គភាពប្រើទស្សនទាននៃអង្គភាពរកសាច់ប្រាក់ក្នុង ស.គ.អ.ក ៣៦ ។

៦១ ភាពដែលអាចរកបាននៃធនធានដើម្បីបំពេញប្រើប្រាស់ និងទទួលបានប្រយោជន៍ពីទ្រព្យសកម្មអរូបិយ អាចត្រូវបង្ហាញតាមរយៈ ឧទាហរណ៍ដូចជា ផែនការអាជីវកម្មដែលបង្ហាញពីបច្ចេកទេស ធនធានហិរញ្ញវត្ថុ និងធនធាន ដទៃទៀតដែលត្រូវការ និងលទ្ធភាពរបស់អង្គភាព ដើម្បីធានា

ធនធាន ទាំងនោះ។ ក្នុងករណីខ្លះ អង្គភាពមួយបង្ហាញពីភាពដែលអាចរកបាន នៃហិរញ្ញវត្ថុផ្នែកខាងក្រៅ តាមរយៈការទទួលបានការចង្អុលបង្ហាញបន្ថែម របស់អ្នកឱ្យខ្ចីអំពីឆន្ទៈរបស់ខ្លួន ដើម្បីផ្តល់ហិរញ្ញប្បទានលើផែនការនោះ។

៦២ ប្រព័ន្ធថ្លៃដើមរបស់អង្គភាពមួយ ជារឿយៗអាចវាស់វែងយ៉ាងគួរឱ្យទុកចិត្តបានពីថ្លៃដើមនៃការបង្កើតនូវទ្រព្យសកម្មអរូបិយផ្នែកខាងក្នុង ដូចជា ប្រាក់បៀវត្ស និងការចំណាយផ្សេងៗទៀតដែលបានកើតឡើង ដើម្បីធានា សិទ្ធិថតចំលង ឬអជ្ញាប័ណ្ណ ឬការបង្កើតឡើងនូវផ្នែកទន់របស់កុំព្យូទ័រ ។

៦៣ **ស្លាកសញ្ញា ចំណងជើងធំៗ ចំណងជើងផ្សាយ បញ្ជីអតិថិជនដែលបង្កើតឡើងផ្ទៃខាងក្រៅ និងធាតុផ្សេងទៀតដែលប្រហាក់ប្រហែលនៅក្នុងស្ថានភាពពិតមិនត្រូវបានទទួលស្គាល់ជា ទ្រព្យសកម្មអរូបិយ។**

៦៤ ចំណាយទៅលើការបង្កើត ស្លាកសញ្ញា យីហោ ចំណងជើងដែលបាន បោះពុម្ពផ្សាយបញ្ជីរាយនាមអតិថិជន និងធាតុដែលស្រដៀងគ្នា ស្ថិតក្នុង ស្ថានភាពពិតមិនត្រូវបានញែកចេញឱ្យដាច់ពីគ្នា រវាងថ្លៃដើមនៃការ បង្កើតអាជីវកម្មទាំងមូលទេ។ដូច្នេះធាតុទាំងនោះមិនត្រូវទទួលស្គាល់ថាជាទ្រព្យសកម្មអរូបិយទេ ។

## ថ្លៃដើមនៃទ្រព្យសកម្មអរូបិយដែលកើតឡើងនៅផ្ទៃខាងក្នុង

៦៥ ថ្លៃដើមនៃទ្រព្យសកម្មអរូបិយដែលបង្កើតឡើងដោយផ្នែកខាងក្នុង សម្រាប់គោលបំណងនៃកថាខណ្ឌ ២៤ គឺជាចំនួនសរុបនៃការចំណាយដែលបានកើតមានឡើងពីកាលបរិច្ឆេទដែលទ្រព្យសកម្មអរូបិយជាដំបូងបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់នៅក្នុងកថាខណ្ឌ ២១-២២ និង

៥៧។ កថាខណ្ឌ ៧១ ហាមឃាត់ ការបង្ហាញឡើងវិញនៃការចំណាយ ដែលបានទទួលស្គាល់ថាជាចំណាយនៅក្នុងឆ្នាំកន្លងរួចមកហើយ ។

៦៦ ថ្លៃដើមរបស់ទ្រព្យសកម្មអរូបិយដែលបង្កើតឡើងដោយផ្ទៃកខាងក្នុង រួមបញ្ចូលថ្លៃដើមផ្ទាល់ចាំបាច់ទាំងឡាយ ដើម្បីបង្កើតផលិត និងរៀបចំទ្រព្យ-សកម្មនោះ ដើម្បីអាចប្រតិបត្តិការបាន ដែលជាការចង់បានរបស់គណៈគ្រប់គ្រង ។ ឧទាហរណ៍ ថ្លៃដើមដោយផ្ទាល់ គឺ

(ក) ថ្លៃដើមនៃវត្ថុធាតុដើម និងសេវាដែលប្រើឬប្រើប្រាស់នៅក្នុងការបង្កើតទ្រព្យសកម្មអរូបិយ

(ខ) ថ្លៃដើមនៃអត្ថប្រយោជន៍និយោជិក (ដូចបានកំណត់ក្នុង ស.គ.អ.ក ១៩) ដែលកើតឡើងពីការបង្កើតឡើងនូវទ្រព្យសកម្មអរូបិយ។

(គ) ថ្លៃឈ្នួលនៅចុះបញ្ជីសិទ្ធិស្របច្បាប់ និង

(ឃ) ការរំលស់លើអាជ្ញាប័ណ្ណ និងប្រកាសណីយប័ត្រដែលបានប្រើប្រាស់ក្នុងការបង្កើតឡើងនូវទ្រព្យសកម្មអរូបិយ។

ស.គ.អ.ក ២៣ បញ្ជាក់ពីលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ការប្រាក់ ជាសមាសធាតុនៃថ្លៃដើមនៃទ្រព្យសកម្មអរូបិយដែលបានបង្កើតឡើងដោយផ្ទៃកខាងក្នុង។

៦៧ ខាងក្រោមនេះមិនមែនជាសមាសធាតុនៃថ្លៃដើម សម្រាប់ទ្រព្យសកម្មអរូបិយដែលត្រូវបានបង្កើតឡើងដោយផ្ទៃកខាងក្នុងទេៈ

(ក) ការចំណាយលើការលក់ រដ្ឋបាល និងការចំណាយផ្សេងៗទូទៅ លើកលែងតែចំណាយទាំងនេះ អាចចូលរួមដោយផ្ទាល់ សម្រាប់ការរៀបចំទ្រព្យសកម្មដើម្បីប្រើប្រាស់។

(ខ) អប្រសិទ្ធភាពដែលបានកំណត់ និងការខាតបង់ពីប្រតិបត្តិការអាជីវកម្មដំបូង មុនពេលទ្រព្យសកម្មមួយសម្រេចបានលទ្ធផលដូចគ្រោងទុក និង

(គ) ការចំណាយបណ្តុះបណ្តាលបុគ្គលិកដើម្បីប្រើប្រាស់ទ្រព្យសកម្ម។

ការបង្ហាញដោយឧទាហរណ៍ក្នុងកថាខណ្ឌ ៦៥

*អង្គភាពមួយកំពុងតែបង្កើតដំណើរការផលិតកម្មថ្មីមួយ។ ក្នុងអំឡុងឆ្នាំ ២០X៥ការចំណាយដែលបានធ្វើឡើងមាន១០០០(ក) ដែលក្នុងចំណាយនេះមាន ៩០០ បានកើតឡើងមុនថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០X៥ ហើយ ១០០ កើតឡើងនៅក្នុងរវាងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០X៥ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៥។ អង្គភាពអាចចង្អុលបង្ហាញបានថានៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០X៥ ដំណើរការផលិតកម្មបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ជាទ្រព្យសកម្មអរូបិយមួយ។ ចំនួនដែលអាចទទួលវិញបានដោយផ្អែកលើ ចំណេះដឹងដែលបានភ្ជាប់ទៅនឹងដំណើរការ (រួមបញ្ចូលលំហូរចេញនៃសាច់ប្រាក់នាពេលអនាគត ដើម្បីបញ្ចប់ដំណើរការមុនពេលដែលកើតមានសម្រាប់ការប្រើប្រាស់) ត្រូវបានគេរំពឹងថាមានតម្លៃ ៥០០ ។*

*នៅចុងឆ្នាំ២០ X៥ ដំណើរការផលិតកម្មត្រូវបានទទួលស្គាល់ថាជាទ្រព្យសកម្មអរូបិយដែលមានតម្លៃ ១០០ (ការចំណាយដែលបានកើតឡើងតាំងពីថ្ងៃដែលលក្ខណៈវិនិច្ឆ័យ ត្រូវបានបំពេញដើម្បីទទួលស្គាល់នូវគឺនៅ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០X៥) ហើយចំណាយចំនួន ៩០០ បានកើតឡើងមុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០ X៥ ត្រូវបានទទួលស្គាល់ថា ជា*

ចំណាយពីព្រោះពុំមានការសម្រេចបាននូវលក្ខណៈវិនិច្ឆ័យរហូតដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០X៥ ការចំណាយនេះពុំមែនបង្កើតជាផ្នែកមួយ នៃចំណាយសម្រាប់ដំណើរការផលិតកម្មដែលត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការទេ។

នៅកំឡុងឆ្នាំ២០ X៦ ការចំណាយដែលបានកើតឡើងគឺ ២០០០។ ហើយចុងឆ្នាំ២០ X៦ ចំនួនដែលអាចទទួលបានវិញ ដោយផ្អែកលើចំណេះដឹង ដែលបានភ្ជាប់ទៅនឹងដំណើរការផលិតកម្ម (រួមមានលំហូរចេញនៃសាច់ប្រាក់នាពេលអនាគត ដើម្បីបញ្ចប់ដំណើរការមុនពេលដែលវាអាចប្រើប្រាស់បាន) ត្រូវបានរំពឹងទុកថាមានតម្លៃ ១៩០០ ។ នៅចុងឆ្នាំ២០ X៦ ចំណាយសម្រាប់ដំណើរការផលិតកម្មគឺ២១០០ (ការចំណាយ ១០០ ត្រូវបានទទួល ស្គាល់នៅចុងឆ្នាំ២០ X៥ រួមបញ្ចូលការចំណាយ ២០០០ ដែលបានទទួលស្គាល់នៅឆ្នាំ ២០X៦)។ អង្គភាពទទួលស្គាល់ការខាតបង់ដែលកើតមកពីការខូចខាតមានចំនួន ២០០ ដើម្បីកែតម្រូវចំនួនដែល នៅសល់ពីដំណើរការមុនពេលវាមានការខាតបង់ ដែលបណ្ដាលមកពីការខូចខាត (ចំនួន ២១០០) ទៅនឹងចំនួនដែលអាចទទួលបានវិញរបស់វាដែលមានចំនួន ១៩០០។

(ក) នៅក្នុងស្តង់ដារនេះ ទឹកប្រាក់រូបិយវត្ថុត្រូវបានកំណត់ជាឯកត្តារូបិយវត្ថុមួយ

## ការទទួលស្គាល់ចំណាយ

៦៨ ការចំណាយទៅលើធាតុអរូបិយមួយ ត្រូវបានទទួលស្គាល់ថា ជាចំណាយនៅពេលដែលកើតឡើង លើកលែងតែ:

(ក) វាបង្កើតផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មអរូបិយ ដែលបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ (សូមមើលកថាខណ្ឌ ១៨-៦៧) ឬ

(ខ) ធាតុដែលបានទិញនៅក្នុងការរួមអាជីវកម្មបញ្ចូលគ្នា និងមិនអាចត្រូវបានទទួលស្គាល់ថា ជាទ្រព្យសកម្មអរូបិយទេ ។ ប្រសិនបើនេះជា បញ្ហាមែននោះវាបង្កើតផ្នែកមួយនៃទឹកប្រាក់ដែលបានទទួលស្គាល់ជាមូលនិធិពាណិជ្ជកម្មនៅថ្ងៃទិញ(សូមមើលបន្ថែមស.រ.ហ.អ.ក ៣)។

៦៩ ក្នុងករណីខ្លះ ការចំណាយបានកើតឡើង ដើម្បីផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់អង្គភាពមួយ ប៉ុន្តែគ្មានទ្រព្យសកម្មអរូបិយ ឬទ្រព្យសកម្មផ្សេងទៀតត្រូវបានទិញ ឬ បង្កើតដើម្បីទទួលស្គាល់នោះឡើយ។ ក្នុងករណីនៃការផ្គត់ផ្គង់ទំនិញអង្គភាពទទួលស្គាល់ចំណាយបែបនេះ ជាចំណាយនៅពេលដែលអង្គភាពមានសិទ្ធិប្រើប្រាស់ទំនិញទាំងនោះ ។ នៅក្នុងករណីនៃការផ្គត់ផ្គង់សេវាអង្គភាពទទួលស្គាល់ចំណាយនោះ ជាចំណាយនៅពេលដែលអង្គភាពទទួលបានសេវា ។ ឧទាហរណ៍: ការ ចំណាយទៅលើការស្រាវជ្រាវត្រូវបានទទួលស្គាល់ថាជាចំណាយ នៅពេល ដែលវាបានកើតឡើង (សូមមើល កថាខណ្ឌ ៥៤) លើកលែងតែនៅពេល ដែលទ្រព្យសកម្មត្រូវបានទិញជាផ្នែកមួយនៃការបញ្ចូលអាជីវកម្មរួមគ្នា។ ឧទាហរណ៍ផ្សេងទៀតនៃចំណាយដែលត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលវាកើតឡើងរួមមាន:

(ក) ការចំណាយលើការសកម្មភាពចាប់ផ្ដើម (ពោលគឺ ថ្លៃដើមចាប់ផ្ដើមសកម្មភាព) លើកលែងតែការចំណាយនេះ បានដាក់បញ្ចូលទៅក្នុងថ្លៃដើមនៃធាតុមួយរបស់ទ្រព្យ រោងចក្រ និងបរិក្ខារដោយអនុលោមតាម ស.គ.អ.ក ១៦។ ថ្លៃដើមចាប់ផ្ដើម អាចរួមមានថ្លៃនៃការបង្កើតអាជីវកម្ម ដូចជា ថ្លៃដើមផ្នែកច្បាប់ និងថ្លៃដើមផ្នែកលេខាធិការ ដែលបានកើតឡើងក្នុងការបង្កើតអង្គភាពស្របច្បាប់មួយការចំណាយលើការបើករោងចក្រ ឬអាជីវកម្មថ្មីមួយ (ពោលគឺ ថ្លៃដើមមុនការបើកដំណើរការ) ឬ ការចំណាយសម្រាប់ការចាប់ផ្ដើមកិច្ចប្រតិបត្តិការ ឬយុទ្ធនាការលើផលិតផលថ្មី ឬ ដំណើរការថ្មី (ថ្លៃដើមប្រតិបត្តិការ)។

(ខ) ការចំណាយលើសកម្មភាពបណ្ដុះបណ្ដាល។

(គ) ការចំណាយលើសកម្មភាពនៃការផ្សព្វផ្សាយនិងផ្សាយ ពាណិជ្ជកម្ម។

(ឃ) ការចំណាយលើការផ្លាស់ប្ដូរទីតាំង ឬរៀបចំឡើងវិញនូវផ្នែកខ្លះ ឬទាំងស្រុងរបស់អង្គភាពមួយ។

៦៩ក អង្គភាពមួយមានសិទ្ធិដើម្បីប្រើប្រាស់ទំនិញ នៅពេលដែលអង្គភាពកាន់កាប់ពួកគេ ។ ស្រដៀងគ្នានេះ អង្គភាពមានសិទ្ធិដើម្បីប្រើប្រាស់ទំនិញ នៅពេលដែលទំនិញត្រូវបានសាងសង់ដោយអ្នកផ្គត់ផ្គង់ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចសន្យាផ្គត់ផ្គង់ ហើយអង្គភាពអាចទាមទារឱ្យមាន ការប្រគល់ទំនិញជាថ្នូរនឹងការទូទាត់ ។ សេវាត្រូវបានទទួលនៅពេលសេវាត្រូវបានអនុវត្តដោយអ្នកផ្គត់ផ្គង់ដោយអនុលោមតាមកិច្ចសន្យាដើម្បីប្រគល់សេវាទៅឱ្យអង្គភាព និងនៅពេលដែលអង្គភាពប្រើប្រាស់សេវា

ដើម្បីប្រគល់សេវាផ្សេងទៀត ជាឧទាហរណ៍ផ្តល់សេវាផ្សព្វផ្សាយទៅឱ្យអតិថិជន ។

៧០ កថាខណ្ឌ ៦៨ មិនហាមឃាត់អង្គភាពមួយពីការទទួលស្គាល់ការបង់មុនជាទ្រព្យសកម្មបានទេ នៅពេលដែល ការទូទាត់សម្រាប់ទំនិញត្រូវបានធ្វើឡើងជាមុនដើម្បីទទួលសិទ្ធិប្រើប្រាស់ទំនិញទាំងនោះ ។ ស្រដៀងគ្នានេះ កថាខណ្ឌ ៦៨ មិនហាមឃាត់អង្គភាពមួយពីការទទួលស្គាល់ការបង់មុន ជាទ្រព្យសកម្មនៅពេលដែលការទូទាត់សម្រាប់សេវាត្រូវបានធ្វើឡើងជា មុននៃអង្គភាពដែលនឹងទទួលសេវាទាំងនោះ។

**ចំណាយអតីតកាលមិនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មទេ**

**៧១ ការចំណាយលើធាតុអរូបិយដែលទទួលបានទទួលស្គាល់ជាដំបូងថាជាចំណាយ នឹង មិនត្រូវបានទទួលស្គាល់ជាផ្នែកមួយនៃថ្លៃដើមរបស់ទ្រព្យសកម្មអរូបិយ នោះទេនៅកាលបរិច្ឆេទបន្ទាប់ ។**

## ការវាស់វែងក្រោយពេលទទួលស្គាល់

**៧២ អង្គភាពនឹងជ្រើសរើសទាំងវិធីសាស្ត្រថ្លៃដើមក្នុងកថាខណ្ឌ ៧៤ ឬវិធីសាស្ត្រវាយតម្លៃឡើងវិញ ក្នុងកថាខណ្ឌ ៧៥ ជាគោលនយោបាយគណនេយ្យរបស់ខ្លួន។ ប្រសិនបើទ្រព្យសកម្មអរូបិយ ត្រូវបានធ្វើគណនេយ្យកម្មតាមវិធីសាស្ត្រវាយតម្លៃឡើងវិញនោះ គ្រប់ទ្រព្យសកម្មទាំងអស់ផ្សេងទៀតថ្នាក់ក៏ត្រូវធ្វើការវាយតម្លៃដោយប្រើប្រាស់វិធីសាស្ត្រដូចគ្នា លើកលែងតែមិនមានទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មទាំងនោះ ។**

៧៣ ថ្នាក់មួយនៃទ្រព្យសកម្មអរូបិយ គឺធ្វើការចាត់ថ្នាក់ទ្រព្យសកម្មជាក្រុមនៃប្រភេទ និងប្រើប្រាស់ស្រដៀងគ្នានៅក្នុងកិច្ចប្រតិបត្តិការរបស់អង្គភាព។ ធាតុទាំងឡាយនៅក្នុងចំណាត់ថ្នាក់នៃទ្រព្យសកម្មអរូបិយ ត្រូវបានវាយតម្លៃជាថ្មីក្នុងពេលតែមួយ ដើម្បីជៀសវាងនូវការវាយតម្លៃទ្រព្យសកម្មដែលជ្រើសរើស និងការរាយការណ៍នូវចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយធ្វើការបង្ហាញបញ្ចូលគ្នានៃថ្លៃដើមនិងតម្លៃក្នុងកាលបរិច្ឆេទផ្សេងគ្នា។

## វិធីសាស្ត្រថ្លៃដើម

៧៤ បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មអរូបិយនឹងត្រូវកត់ត្រាតាមថ្លៃដើម ដោយដកចេញនូវតម្លៃ រំលស់សរុបបូកបន្ត និងការខាតបង់តម្លៃបូកបន្ត ។

## វិធីសាស្ត្រវាយតម្លៃឡើងវិញ

៧៥ បន្ទាប់ពីទទួលស្គាល់លើកដំបូង ទ្រព្យសកម្មអរូបិយនឹងត្រូវបានកត់ត្រាតាមតម្លៃវាយតម្លៃឡើងវិញ ដែលជាតម្លៃសមស្របនៅថ្ងៃវាយតម្លៃដោយដកចេញ តម្លៃរំលស់បូកបន្តក្នុងការិយបរិច្ឆេទបន្ទាប់ និងដកចេញនូវតម្លៃខាតបង់បន្ត។ សម្រាប់គោលបំណងនៃការវាយតម្លៃឡើងវិញដែលស្ថិតក្រោមស្តង់ដានេះ តម្លៃសមស្របនឹងត្រូវកំណត់ឡើងដោយយោងទៅលើទីផ្សារ ដ៏សកម្ម។ ការវាយតម្លៃឡើងវិញនឹងត្រូវធ្វើឡើងជាប្រចាំ ដែលតម្លៃយោង នៃទ្រព្យសកម្ម មិនមានភាពខុសគ្នាជាសារវ័ន្ត ពីតម្លៃសមស្របនៅចុងការិយបរិច្ឆេទរាយការណ៍ ។

៧៦ វិធីសាស្ត្រវាយតម្លៃឡើងវិញ មិនអនុញ្ញាតៈ

(ក) ការវាយតម្លៃឡើងវិញនៃទ្រព្យសកម្មអរូបិយ ដែលមិនបានទទួលស្គាល់ជាដំបូងជាទ្រព្យសកម្ម ឬ

(ខ) ការទទួលស្គាល់ដំបូង នៃទ្រព្យសកម្មអរូបិយតាមចំនួនទឹកប្រាក់ដែល មិនមែនជាថ្លៃដើម

៧៧ វិធីសាស្ត្រវាយតម្លៃឡើងវិញ ត្រូវបានអនុវត្តបន្ទាប់ពីទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ជាលើកដំបូងតាមថ្លៃដើម ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានតែផ្នែកនៃថ្លៃដើមនៃទ្រព្យសកម្មអរូបិយ ត្រូវបានទទួលស្គាល់ ជាទ្រព្យសកម្ម ដោយសារតែទ្រព្យសកម្មនោះ មិនបានបំពេញលក្ខណៈ វិនិច្ឆ័យសម្រាប់ការទទួលស្គាល់ រហូតដល់ផ្នែកនៃដំណើរបង្កើតឡើងនូវ ទ្រព្យសកម្ម (សូមមើលកថាខណ្ឌ ៦៥) នោះវិធីសាស្ត្រវាយតម្លៃឡើងវិញ អាចត្រូវបានប្រើទៅលើទ្រព្យសកម្មទាំងមូល ។ ជាមួយគ្នានេះដែរ វិធីសាស្ត្រវាយតម្លៃឡើងវិញ អាចអនុវត្តចំពោះទ្រព្យសកម្មអរូបិយដែលទទួលបានពីការផ្តល់ឱ្យដោយរដ្ឋាភិបាល ហើយបានទទួលស្គាល់តាម ទឹកប្រាក់តួចតាច (សូមមើលកថាខណ្ឌ (៤៤) ។

៧៨ វាមិនមែនជាទូទៅទេសម្រាប់ទីផ្សារសកម្មជាមួយនឹងចរិកលក្ខណៈដូចបានពិពណ៌នាក្នុងកថាខណ្ឌ ៨ ដើម្បីបង្កើតឱ្យមាននូវទ្រព្យសកម្មអរូបិយ ទោះបី ជាករណីនេះ អាចកើតឡើងក៏ដោយ ។ ឧទាហរណ៍នៅក្នុងប្រទេសខ្លះ ទីផ្សារសកម្មអាចកើតមានឡើង សម្រាប់អាជ្ញាប័ណ្ណតាកស៊ីអាជ្ញាបណ្ណនេសាទ ឬការកំណត់ចំនួនផលិតកម្មដែលអាចផ្ទេរបានដោយសេរី ។ ទោះជាយ៉ាងក៏ដោយ ទីផ្សារសកម្មមិនអាចកើតមានឡើងទេ ចំពោះស្លាកសញ្ញាការផ្សព្វផ្សាយសិទ្ធិក្នុងការផលិតខ្សែភាពយន្តកម្មសិទ្ធិបញ្ញា ឬស្លាកសញ្ញាពាណិជ្ជកម្ម ពីព្រោះទ្រព្យសកម្មនីមួយៗមានតែមួយ ។ ជាមួយគ្នានេះដែរ

ទោះបីជាទ្រព្យសកម្មអរូបិយត្រូវបានទិញ ឬលក់ក៏ដោយក៏កិច្ចសន្យាត្រូវបាន ធ្វើឡើងដោយអ្នកលក់និងអ្នកទិញ ហើយប្រតិបត្តិការទាំងនោះ មិនកើត ឡើងញឹកញាប់។ សម្រាប់ហេតុផលនេះ តម្លៃដែលត្រូវបង់សម្រាប់ទ្រព្យសកម្មនីមួយៗ មិនផ្តល់នូវភស្តុងតាងគ្រប់គ្រាន់សម្រាប់តម្លៃសមស្រប ។ ជាងនេះទៅទៀត តម្លៃជារឿយៗមិនត្រូវបានទទួលយកដោយទីផ្សារនោះ ទេ ។

៧៩ ភាពញឹកញាប់នៃការវាយតម្លៃឡើងវិញ អាស្រ័យលើភាពងាយប្រែប្រួលនៃថ្លៃទីផ្សាររបស់ទ្រព្យសកម្មអរូបិយ ដែលត្រូវវាយតម្លៃ ។ ប្រសិនបើថ្លៃទីផ្សា រនៃទ្រព្យសកម្មដែលត្រូវវាយតម្លៃឡើងវិញ ខុសគ្នាជាសារវ័ន្តពីតម្លៃយោង នោះ ការវាយតម្លៃបន្ថែមទៀតមានភាពចាំបាច់ ។ ទ្រព្យសកម្មអរូបិយខ្លះ អាចមានចលនាប្រែប្រួលខ្លាំងក្នុងតម្លៃសមស្របដែលករណីនេះភាពចាំ បាច់នៃការវាយតម្លៃប្រចាំឆ្នាំ ។ ការវាយតម្លៃឡើងវិញជាញឹកញាប់មិនមាន ភាពចាំបាច់សម្រាប់ទ្រព្យសកម្មអរូបិយជាមួយនឹងការប្រែប្រួលមិនសំខាន់នៅ ក្នុងតម្លៃសមស្រប ។

៨០ ប្រសិនបើទ្រព្យសកម្មអរូបិយត្រូវបានវាយតម្លៃឡើងវិញនោះ តម្លៃរំលស់បូកបន្តនៅថ្ងៃវាយតម្លៃឡើងវិញគឺៈ

(ក) ត្រូវបានបង្ហាញឡើងវិញតាមសមាមាត្រជាមួយនឹងការផ្លាស់ប្តូរ នូវតម្លៃយោងនៃទ្រព្យសកម្មដែលតម្លៃយោងនោះ ធ្វើឡើងបន្ទាប់ ពីការវាយតម្លៃឡើងវិញ ដោយស្មើនឹងទឹកប្រាក់វាយតម្លៃរួច ឬ

(ខ) ត្រូវបានលុបចោលទល់នឹងតម្លៃយោងដុលនៃទ្រព្យសកម្ម និងតម្លៃពិត ដែលធ្វើត្រូវបានរាយការណ៍ឡើងវិញតាមទឹកប្រាក់វាយតម្លៃឡើងវិញនៃទ្រព្យសកម្ម ។

៨១ ប្រសិនបើទ្រព្យសកម្មអរូបិយ ស្ថិតនៅក្នុងថ្នាក់នៃទ្រព្យសកម្មដែលវាយតម្លៃឡើងវិញមិនអាចវាយតម្លៃឡើងវិញបានទេដោយសារតែពុំមានទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មទាំងនេះ នោះទ្រព្យសកម្មនឹងត្រូវកត់ត្រាតាម ថ្លៃដើមដោយដកចេញនូវតម្លៃរំលស់បន្ត និងការខាតបង់ដោយសារ ថយចុះនៃតម្លៃ ។

៨២ ប្រសិនបើតម្លៃសមស្រប នៃទ្រព្យសកម្មអរូបិយដែលវាយតម្លៃឡើងវិញលែងអាចត្រូវបានកំណត់ទៅតាមទីផ្សារសកម្ម នោះតម្លៃយោងនៃទ្រព្យ-សកម្ម នឹងត្រូវធ្វើការវាយតម្លៃឡើងវិញ នៅថ្ងៃដែលវាយតម្លៃឡើងវិញ ចុងក្រោយ តាមទីផ្សារសកម្ម ដោយដកចេញនូវតម្លៃរំលស់បូក និងការខាត បង់ដោយសារការថយចុះតម្លៃបង្គរ ជាបន្តបន្ទាប់ ។

៨៣ ការពិតដែលទីផ្សារសកម្មមិនកើតឡើងទៀតទេ សម្រាប់ទ្រព្យសកម្មអរូបិយដែលបានវាយតម្លៃឡើងវិញ អាចបង្ហាញថា ទ្រព្យសកម្មអាចថយចុះតម្លៃហើយថា ទ្រព្យសកម្មនោះនឹងត្រូវធ្វើបានធ្វើតេស្តដោយយោងតាម ស.គ. អ.ក៣៦ ។

៨៤ ប្រសិនបើតម្លៃសមស្របនៃទ្រព្យសកម្ម អាចត្រូវបានកំណត់ដោយយោងទៅតាមទីផ្សារសកម្ម នៅថ្ងៃវាស់វែងបន្តបន្ទាប់នោះវិធីសាស្ត្រវាយតម្លៃឡើងវិញ ត្រូវបានប្រើចាប់ពីកាលបរិច្ឆេទនោះ ។

៨៥ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មអរូបិយមានការកើនឡើង ដែលជាលទ្ធផល នៃការវាយតម្លៃឡើងវិញ នោះការកើនឡើងនឹងត្រូវចុះខាងឥណទាននៃ គណនីមូលធន ក្រោមគណនីឈ្មោះអតិរេកពីការវាយតម្លៃឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយការកើនឡើងនឹងត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ-ខាត តាមទំហំដែលវាបញ្ច្រាស់ការថយចុះនៃការវាយតម្លៃ ឡើង

វិញរបស់ទ្រព្យសកម្មដូចគ្នា ដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញខាត ពីលើកមុន ។

**៨៦ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មអរូបិយមានការថយចុះដែលជាលទ្ធផលនៃការវាយតម្លៃឡើងវិញ នោះការថយចុះនឹងត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញខាត ។ ទោះជាយ៉ាងណាក៏ដោយ ការថយចុះត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតតាមទំហំនៃសមតុល្យខាងឥណទាននៅក្នុងអតិរេកពីការវាយតម្លៃទាក់ទិននឹងទ្រព្យសកម្មនោះ ។ ការថយចុះដែលបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតកាត់បន្ថយទឹកប្រាក់ដែលបានប្តូកបន្តនៅក្នុង គណនីមូលធនក្រោម គណនីឈ្មោះអតិរេក ពីការវាយតម្លៃ ។**

៨៧ អតិរេកពីការវាយតម្លៃឡើងវិញ ប្តូកបន្តដែលបានចាត់បញ្ចូលក្នុងក្រុមគណនី មូលធនអាចត្រូវបានផ្ទេរដោយផ្ទាល់ទៅគណនីប្រាក់ចំណេញរក្សាទុកនៅពេលដែលអតិរេកមានភាពពិតប្រាកដ។អតិរេកទាំងមូល អាចក្លាយជាភាពពិតប្រាកដទាំងអស់ នៅពេលទ្រព្យសកម្មត្រូវបានឈប់ប្រើប្រាស់ឬលក់ចេញ។ទោះជាយ៉ាងណាក៏ដោយផ្នែកខ្លះនៃអតិរេកអាចត្រូវបានចាត់ថា មានពិតប្រាកដនៅពេលទ្រព្យសកម្មត្រូវបានប្រើប្រាស់ដោយអង្គភាពក្នុងករណីនេះ ទឹកប្រាក់នៃអតិរេកដែលក្លាយទៅជាពិតប្រាក គឺជាភាពខុសគ្នារវាងតម្លៃរំលស់ដោយផ្អែកលើតម្លៃយោងនៃទ្រព្យសកម្មដែលបានវាយតម្លៃឡើងវិញនិងរំលស់ដែលនឹងត្រូវបានទទួលស្គាល់ដោយផ្អែកលើថ្លៃដើមដំបូងរបស់ទ្រព្យសកម្ម។ការផ្ទេរចេញពីអតិរេកនៃការវាយតម្លៃឡើងវិញទៅគណនីប្រាក់ចំណេញរក្សាទុកគឺមិនត្រូវធ្វើឡើងតាមរយៈរបាយកាណ៍ លទ្ធផលនោះទេ ។

៨៨ **អង្គភាពត្រូវវាយតម្លៃថា តើអាយុកាលនៃទ្រព្យសកម្មអរូបិយអាចកំណត់ ឬមិនអាចកំណត់បាន ហើយប្រសិនបើ អាចកំណត់បាននោះ រយៈពេល ឬចំនួនផលិតកម្ម ឬ បរិមាណស្រដៀងនឹងត្រូវបន្តក្នុងអាយុកាលប្រើប្រាស់ ។ ទ្រព្យសកម្មអរូបិយនឹងត្រូវទទួលស្គាល់ដោយអង្គភាព ក្នុងករណីដែលមានអាយុកាលមិនកំណត់ ដោយផ្អែកទៅលើការវិភាគនៃកត្តាដែលជាប់ពាក់ព័ន្ធ ក្នុងអំឡុងពេលដែលទ្រព្យសកម្ម ត្រូវបានរំពឹងទុកថានឹងបង្កើតលំហូរសាច់ប្រាក់ពិតចូលអង្គភាពបាន ។**

៨៩ គណនេយ្យសម្រាប់ទ្រព្យសកម្មអរូបិយ គឺពឹងផ្អែកទៅលើអាយុកាលនៃការប្រើប្រាស់ ។ ទ្រព្យសកម្មអរូបិយជាមួយនឹងអាយុកាលមានកំណត់នឹងត្រូវកាត់រំលស់ (សូមមើលកថាខណ្ឌ ៩៧-១០៦) ហើយទ្រព្យសកម្មអរូបិយជាមួយនឹងអាយុកាលមិនកំណត់ មិនត្រូវកាត់រំលស់នោះទេ (សូមមើលកថាខណ្ឌ ១០៧-១១០) ។ ឧទាហរណ៍បែបពន្យល់ ដែលភ្ជាប់ជាមួយ ស្តង់ដានេះ ចង្អុលបង្ហាញពីការកំណត់អាយុកាលប្រើប្រាស់របស់ទ្រព្យ សកម្មអរូបិយផ្សេងៗគ្នា ហើយគណនេយ្យបន្តបន្ទាប់សម្រាប់ទ្រព្យសកម្ម ទាំងនោះផ្អែកលើការកំណត់អាយុកាលប្រើប្រាស់ ។

៩០ កត្តាជាច្រើន ត្រូវបានពិចារណានៅក្នុងការកំណត់អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយ ដោយរួមមានៈ

(ក) ការប្រើប្រាស់ដែលបានរំពឹងទុកនៃទ្រព្យសកម្មដោយអង្គភាព និង ថាតើទ្រព្យសកម្មអាចត្រូវបានចាត់ចែងប្រកបដោយប្រសិទ្ធិភាព ដោយគណៈគ្រប់គ្រងដែរឬទេ?

(ខ) វដ្តជីវិតនៃផលិតផលផ្សេងគ្នាសម្រាប់ទ្រព្យសកម្ម ហើយព័ត៌មាន ជាសាធារណៈលើការព្យាករណ៍ នៃអាយុកាលប្រើប្រាស់សម្រាប់ ប្រភេទទ្រព្យសកម្មស្រដៀងគ្នា អាចត្រូវបានប្រើប្រាស់ក្នុងស្ថាន ភាពប្រហែលគ្នា ។

(គ) ភាពហួសសម័យនៃបច្ចេកទេសពាណិជ្ជកម្ម ឬប្រភេទផ្សេងទៀត។

(ឃ) ស្ថេរភាពនៃឧស្សាហកម្ម ដែលទ្រព្យសកម្មមានកិច្ចប្រតិបត្តិការ និងមានការផ្លាស់ប្តូរនៅក្នុងតម្រូវការទីផ្សារ សម្រាប់ផលិតផល ឬទិន្នផលសេវាកម្ម ដែលបានមកពីទ្រព្យសកម្មនោះ

(ង) សកម្មភាពរំពឹងទុកដោយគូប្រកួតប្រជែង ឬគូប្រកួតប្រជែងដែល មានសក្តានុពល

(ច) កម្រិតចំណាយថែទាំ តម្រូវឱ្យមានដើម្បីទទួលបានអត្ថប្រយោជន៍ ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ដែលកើតចេញពីទ្រព្យសកម្មទាំង នោះ ហើយលទ្ធភាព និងការរក្សាទុករបស់អង្គភាព នឹងឈានទៅ ដល់កម្រិតមួយ ។

(ឆ) ការិយបរិច្ឆេទនៃការគ្រប់គ្រងលើទ្រព្យសកម្ម និងការកម្រិតតាម ផ្លូវច្បាប់ឬស្រដៀងគ្នា លើការប្រើប្រាស់ទ្រព្យសកម្ម ដូចជាកាល បរិច្ឆេទហួសកំណត់នៃភតិសន្យាដែលទាក់ទិន និង

(ជ) ថាតើអាយុកាលទ្រព្យសកម្មពឹងផ្អែកលើអាយុកាលនៃទ្រព្យសកម្ម ផ្សេងទៀតរបស់អង្គភាពដែរឬទេ ?

៩១ វាក្យស័ព្ទ ” មិនអាចកំណត់បាន ” មិនមានន័យថា” គ្មានដែនកំណត់ ” នោះទេ ។ អាយុកាលនៃការប្រើប្រាស់ ឆ្លុះបញ្ចាំងកម្រិតចំណាយថែទាំនាពេលអនាគតដែលតម្រូវឱ្យមានដើម្បីថែទាំទ្រព្យសកម្ម តាមស្តង់ដានៃការប្រើប្រាស់ ដែលបានវាយតម្លៃនៅពេលប៉ាន់ស្មានអាយុកាលនៃទ្រព្យសកម្ម ហើយលទ្ធភាពរបស់អង្គភាព និងការរក្សាទុកដើម្បីសម្រេចបាននូវកម្រិតមួយ ។ សេចក្តីសន្និដ្ឋានដែលអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មអរូបិយមិនអាចកំណត់បាន មិនគួរពឹងផ្អែកទៅលើផែនការចំណាយនាពេលអនាគត លើសពីចំណាយដែលតម្រូវឱ្យមានដើម្បីថែទាំទ្រព្យសកម្មតាមស្តង់ដារនៃការអនុវត្តនោះ ។

៩២ ដោយដឹងថាប្រវត្តិនៃការផ្លាស់ប្តូរយ៉ាងលឿនខាងផ្នែកបច្ចេកវិជ្ជា ផ្នែកទន់របស់កុំព្យូទ័រ និងទ្រព្យសកម្មអរូបិយដទៃទៀត ដែលនាំឱ្យឆាប់ហួសសម័យផ្នែកបច្ចេកវិជ្ជា។ ហេតុដូច្នេះ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយ ទាំងនោះមានអាយុកាលខ្លី ។

៩៣ អាយុប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយ អាចមានរយៈពេលយូរ ឬកំណត់មិនបានតែម្តង។ភាពមិនប្រាកដប្រជា ធ្វើការកែតម្រូវលើការប៉ាន់ប្រមាណអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយផ្អែកលើមូលដ្ឋានប្រុងប្រយ័ត្នមួយ ប៉ុន្តែមិនកែតម្រូវក្នុងការជ្រើសរើសអាយុកាលមួយ ដែលខ្លីហួសពីការពិតនោះទេ ។

**៩៤ អាយុកាលប្រើប្រាស់ទ្រព្យសកម្មអរូបិយ ដែលកើតឡើងពីកិច្ចសន្យា និងសិទ្ធិ ស្របច្បាប់ នឹងមិនអាចលើស កាលបរិច្ឆេទនៃកិច្ចសន្យា ឬសិទ្ធិស្របច្បាប់ នោះទេ ប៉ុន្តែអាចមានរយៈពេលខ្លីជាងអំឡុងពេលដែលអង្គភាព រំពឹងទុក ក្នុងការប្រើប្រាស់ទ្រព្យសកម្មទាំងនោះ ។ ប្រសិនបើកិច្ចសន្យា ឬសិទ្ធិ**

ស្រប ច្បាប់ដទៃទៀត បានកំណត់លក្ខខណ្ឌនៃកិច្ចសន្យាថា អាចបន្តជាថ្មីទៀត បាន នោះអាយុកាលនៃទ្រព្យសកម្មអរូបិយនឹងត្រូវដាក់បញ្ចូលនូវការិយ- បរិច្ឆេទបន្តជាថ្មីទៀត តែប្រសិនបើមានភស្តុតាងបញ្ជាក់ ពីរយៈពេលបន្ត ជាថ្មី ដោយអង្គភាពទោះបីជាមិនមានថ្លៃដើមសំខាន់ក៏ដោយ ។ អាយុកាល ប្រើប្រាស់នៃសិទ្ធិដែលបានទិញឡើងវិញដែលបានទទួលស្គាល់ជាទ្រព្យសកម្មអរូបិយនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា គឺជាការិយបរិច្ឆេទតាមកិច្ចសន្យាដែលនៅសល់ ដែលសិទ្ធិត្រូវបានគេផ្តល់និងមិនត្រូវបានបញ្ចូលនៅក្នុងការិយបរិច្ឆេទបន្តថ្មីទៀតទេ។

៩៥ អាចមានទាំងកត្តាច្បាប់ និងកត្តាសេដ្ឋកិច្ចដែលជះឥទ្ធិពលទៅដល់អាយុកាលប្រើប្រាស់នៃទ្រព្យសកម្មអរូបិយ។ កត្តាសេដ្ឋកិច្ចកំណត់អំពីការិយ-បរិច្ឆេទ ដែលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគតនឹងត្រូវទទួលបានដោយអង្គភាព ។ កត្តាច្បាប់អាចកំណត់ពីការិយបរិច្ឆេទដែលអង្គភាពគ្រប់គ្រង ដើម្បីទទួលបាននូវអត្ថប្រយោជន៍ ។ អាយុកាលប្រើប្រាស់មានលក្ខណៈ ខ្លីជាង ការិយបរិច្ឆេទដែលកំណត់ដោយកត្តាទាំងនេះ ។

៩៦ ការកើតមានឡើងនូវកត្តាទាំងឡាយខាងក្រោមក្នុងចំណោមកត្តាផ្សេងទៀតដែលកើតមានដូចខាងក្រោម បង្ហាញថាអង្គភាពអាចបន្ត កិច្ចសន្យា ឬសិទ្ធិស្របច្បាប់ជាថ្មី ដោយមិនមានថ្លៃដើមសំខាន់:

(ក) មានភស្តុតាង ដែលពឹងផ្អែកលើបទពិសោធន៍ ដែលកិច្ចសន្យា ឬសិទ្ធិស្របច្បាប់អាចបន្តសារជាថ្មីបាន ។ ប្រសិនបើការបន្តនោះជាប់ពាក់ព័ន្ធទៅនឹងការយល់ព្រមពីភាគីទីបី នោះករណីនេះរួមបញ្ចូលនូវភស្តុតាង ដែលភាគីទីបីនឹងផ្តល់ការ យល់ព្រម ។

(ខ) មានភស្តុតាងដែលថា រាល់លក្ខខណ្ឌណាមួយ ដែលចាំបាច់ដើម្បីទទួលស្គាល់នូវការបន្តកិច្ចសន្យា ឬសិទ្ធិស្របច្បាប់នឹងត្រូវបានបំពេញ ។

(គ) ថ្លៃដើមរបស់អង្គភាពនៅក្នុងការបន្តកិច្ចសន្យា ឬសិទ្ធិស្របច្បាប់សារជាថ្មី មិនសំខាន់នៅពេលប្រៀបធៀបទៅនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចដែលរំពឹងទុកថានឹងទទួលបានដល់អង្គភាពតាមរយៈការបន្តជាថ្មីនោះ។

ប្រសិនបើថ្លៃដើមនៃការបន្តសារជាថ្មីនោះមានសារៈសំខាន់នៅពេលប្រៀបធៀបជាមួយនឹងអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលរំពឹងទុកថានឹងទទួលបាននោះថ្លៃដើមនៃការបន្តតំណាងឱ្យនូវថ្លៃដើម ដែលត្រូវទិញទ្រព្យសកម្មអរូបិយថ្មីនៅថ្ងៃបន្តសារជាថ្មីនោះទៅតាមស្ថានភាពពិត ។

## ទ្រព្យសកម្មអរូបិយជាមួយនឹងអាយុកាលប្រើប្រាស់មានកាលកំណត់

### ការិយបរិច្ឆេទធ្វើរំលស់និងវិធីសាស្ត្រធ្វើរំលស់

**៩៧** **ចំនួនទឹកប្រាក់ដែលអាចរំលស់បាន នៃទ្រព្យសកម្មអរូបិយដែលមានអាយុកាល ប្រើប្រាស់មានកាលកំណត់ នឹងត្រូវបែងចែងទៅតាមមូលដ្ឋានជាប្រព័ន្ធលើ អាយុកាលប្រើប្រាស់របស់វា ។ ការកាត់រំលស់នឹងចាប់ផ្តើមនៅពេល ទ្រព្យ សកម្មអាចប្រើប្រាស់បាន ពោលគឺនៅពេលដែលទ្រព្យសកម្មស្ថិតនៅក្នុង ទីតាំង និងលក្ខខណ្ឌចាំបាច់ ដើម្បីដាក់ឱ្យដំណើរការដោយគណៈគ្រប់គ្រង ។ ការកាត់រំលស់នឹងត្រូវបញ្ចប់នៅដើមកាលបរិច្ឆេទដែលទ្រព្យសកម្មនោះ ត្រូវចាត់ថ្នាក់សម្រាប់ការលក់ (ឬរួមបញ្ចូលក្នុងក្រុមទ្រព្យសកម្មលក់ចោល ដែលត្រូវបានចាត់ទុកសម្រាប់លក់)ដោយយោងតាម ស.រ**

.ហ.អ.ក ៥ និងថ្ងៃដែលទ្រព្យសកម្មឈប់ទទួលស្គាល់វិញ។ វិធីសាស្ត្រកាត់រំលស់ដែល ប្រើប្រាស់ នឹងឆ្លុះបញ្ចាំង ពីទម្រង់ដែលអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេល អនាគតរបស់ទ្រព្យសកម្មត្រូវបានរំពឹងទុក ដើម្បី ប្រើប្រាស់ដោយអង្គភាព។ ប្រសិនបើទម្រង់នោះ មិនត្រូវបានកំណត់ដោយជឿជាក់នោះ វិធីសាស្ត្រដក រំលស់ថេរ នឹងត្រូវបានយកមកប្រើប្រាស់។ តម្លៃនៃការកាត់រំលស់សម្រាប់ ការិយបរិច្ឆេទនីមួយៗ នឹងទទួលស្គាល់ក្នុង របាយការណ៍ចំណេញ-ខាត លើកលែងតែមានស្តង់ដាផ្សេងទៀត អនុញ្ញាត ឬទទួលស្គាល់តម្លៃ កាត់រំលស់នោះ ដើម្បីដាក់បញ្ចូលក្នុងតម្លៃយោងនៃទ្រព្យសកម្ម។

៩៨ វិធីសាស្ត្រកាត់រំលស់ផ្សេងអាចត្រូវបានប្រើប្រាស់ ដើម្បីបែងចែកទឹកប្រាក់អាចរំលស់បាននៃទ្រព្យសកម្មតាមមូលដ្ឋាន ជាប្រព័ន្ធលើអាយុកាលប្រើប្រាស់ ។ វិធីសាស្ត្រទាំងនេះ រួមបញ្ចូលវិធីសាស្ត្ររំលស់ថេរ វិធីសាស្ត្រកាត់បន្ថយសមតុល្យ និងវិធីសាស្ត្រឯកត្តាផលិតកម្ម ។ វិធីសាស្ត្រដែលបានប្រើប្រាស់ ត្រូវបានជ្រើសរើសដោយឈរលើមូលដ្ឋាននៃការរំពឹងទុកសម្រាប់ការប្រើប្រាស់នៃអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលផ្តល់ដោយទ្រពសកម្ម និងត្រូវអនុវត្តប្រកបដោយសង្គតិភាព ពីកាលបរិច្ឆេទមួយទៅកាលបរិច្ឆេទមួយទៀត លើកលែងតែមានការផ្លាស់ប្តូរនៅក្នុង វិធីសាស្ត្រ នៃការប្រើប្រាស់សម្រាប់រំពឹងទុកនូវអត្ថប្រយោជន៍នាពេលអនាគត។ មានលក្ខណៈកម្រ ទោះបីជាមានភស្តុតាងដែលគាំទ្រដល់វិធីសាស្ត្រកាត់រំលស់ សម្រាប់ទ្រព្យសកម្មអរូបិយ ដែលមានអាយុកាលប្រើប្រាស់មានកំណត់ ដែលលទ្ធផលនៃការដករំលស់សរុបមានកម្រិតទាបជាងវិធីសាស្ត្រដករំលស់ថេរក៏ដោយ ។

៩៩ ទឹកប្រាក់រំលស់ជាធម្មតាត្រូវបានទទួលស្គាល់ ក្នុងរបាយការណ៍ចំណេញខាត។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយក៏ពេលខ្លះអត្ថប្រយោជន៍នាពេលអនាគតដែលផ្តល់ដោយទ្រព្យសកម្ម ត្រូវបានស្រូបយកទៅក្នុងការផលិតទ្រព្យសកម្មផ្សេងទៀត។ ក្នុងករណីនេះ បន្ទុកកាត់រំលស់បង្កើតបានផ្នែកមួយនៃថ្លៃដើមនៃទ្រព្យសកម្មផ្សេងទៀត ហើយត្រូវបានដាក់បញ្ចូលក្នុងតម្លៃយោង ។ ឧទាហរណ៍ ទឹកប្រាក់រំលស់នៃទ្រព្យសកម្មអរូបិយ ដែលត្រូវបានប្រើប្រាស់ក្នុងដំណើរការផលិត ត្រូវបានដាក់បញ្ចូលក្នុងតម្លៃយោង នៃសន្និធិ(សូមមើល ស.គ.អ.ក ២*សន្និធិ*)

**តម្លៃកាកសំណល់**

**១០០ តម្លៃកាកសំណល់របស់ទ្រព្យសកម្មអរូបិយ ត្រូវបានសន្មតថាស្មើនឹងសូន្យលើកលែងតែ:**

**(ក) មានការសន្យាដោយភាគីទីបី ដើម្បីទិញទ្រព្យសកម្មនៅពេលបញ្ចប់អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនោះ ។**

**(ខ) មានទីផ្សារសកម្មសម្រាប់ទ្រព្យសកម្មនោះ និង:**

**(១) តម្លៃកាកសំណល់អាចកំណត់បានដោយយោងទៅតាមទីផ្សារនោះ**

**(២) ទំនងថាទីផ្សារបែបនោះអាចនឹងមាននៅពេលចុងបញ្ចប់នៃ អាយុ-កាលប្រើប្រាស់របស់ទ្រព្យសកម្មបញ្ចប់ ។**

១០១ តម្លៃដែលអាចដករំលស់បាននៃទ្រព្យសកម្មមួយដែលមានកាលកំណត់ត្រូវបានគណនាបន្ទាប់ពីដកតម្លៃកាកសំណល់របស់វាចេញ។តម្លៃកាកសំណល់របស់ជាជាងតម្លៃសូន្យបញ្ជាក់ថាអង្គភាពមួយរំពឹងថានឹងលក់ទ្រព្យសកម្មអរូបិយចេញមុនចុងអាយុកាលប្រើប្រាស់របស់វា ។

១០២ ការប៉ាន់ស្មាននៃតម្លៃកាកសំណល់នៃទ្រព្យសកម្ម គឺផ្អែកលើទឹកប្រាក់ដែលនឹងទទួលបានពីការលក់ចោលដោយប្រើប្រាស់តម្លៃដែលមានទូទៅ នៅកាលបរិច្ឆេទលក់នៃនៃការប៉ាន់ស្មានសម្រាប់ការលក់ទ្រព្យសកម្មប្រហាក់ប្រហែលដែលបានដល់ចុងអាយុកាលប្រើប្រាស់របស់វា និងបានធ្វើកិច្ចប្រតិបត្តិក្រោមលក្ខខណ្ឌ ប្រហាក់ប្រហែលទៅនឹងលក្ខខណ្ឌដែលទ្រព្យសកម្មទាំងនោះ ត្រូវបានប្រើ ។ តម្លៃកាកសំណល់ត្រូវបានត្រួតពិនិត្យឡើងវិញ យ៉ាងហោចណាស់នៅដំណាច់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ។ ការផ្លាស់ប្តូរណាមួយនៃតម្លៃកាកសំណល់ ត្រូវបានធ្វើគណនេយ្យកម្មជាការផ្លាស់ប្តូរការ ប៉ាន់ស្មានគណនេយ្យដោយយោងទៅតាម ស.គ.អ.ក ៨ *គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរក្នុងការប៉ាន់ស្មានគណនេយ្យ និងកំហុស* ។

១០៣ តម្លៃកាកសំណល់នៃទ្រព្យអរូបិយអាចនឹងកើនឡើងនូវចំនួនស្មើ ឬ ធំជាងតម្លៃយោងនៃទ្រព្យសកម្ម។ប្រសិនបើដូច្នេះមែនបន្ទុករំលស់នៃទ្រព្យសកម្មស្មើសូន្យលុះត្រាតែតម្លៃកាកសំណល់ថយចុះជាលំដាប់ទាបជាងតម្លៃយោងនៃទ្រព្យសកម្ម ។

**ការពិនិត្យមើលឡើងវិញនូវរយៈពេលនៃការដករំលស់ និងវិធីសាស្ត្រ ធ្វើរំលស់**

**១០៤ វិធីសាស្ត្រដក់រំលស់ និងកាលបរិច្ឆេទនៃការដករំលស់សម្រាប់ទ្រព្យសកម្មអរូបិយ ដែលមានអាយុកាលកំណត់ ត្រូវបានពិនិត្យមើលឡើងវិញ យ៉ាងហោចណាស់មួយដងរៀងរាល់ចុងកាលបរិច្ឆេទហិរញ្ញវត្ថុ ។ ប្រសិនបើ អាយុកាលនៃការប្រើប្រាស់ដែលរំពឹងទុក របស់ទ្រព្យសកម្មខុសគ្នាខ្លាំងពីការ ប៉ាន់ស្មានពីមុន នោះកាលបរិច្ឆេទនៃការធ្វើរំលស់ ត្រូវបានផ្លាស់ប្តូរតាមផងដែរ ។ ប្រសិនបើមានការផ្លាស់ពីគំរូនៃការប្រើប្រាស់ ផលប្រយោជន៍ សេដ្ឋកិច្ច**

**ដែលបានរំពឹងទុកដែលមាននៅក្នុងទ្រព្យសកម្ម ត្រូវបានផ្លាស់ប្តូរ ឱ្យស៊ីគ្នានឹងគំរូដែលបានផ្លាស់ប្តូរនោះ ។ ការផ្លាស់ប្តូរបែបនោះ ត្រូវបាន ធ្វើគណនេយ្យកម្មជាការផ្លាស់ប្តូរនៅក្នុងការប៉ាន់ស្មានគណនេយ្យស្របតាមស្តង់ដា ស.គ.អ.ក ៨ ។**

១០៥ នៅក្នុងអំឡុងពេលនៃអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយ វាអាចក្លាយជាការបង្ហាញឱ្យឃើញថាការប៉ាន់ស្មាន អាយុកាលប្រើប្រាស់របស់វា មិនមានលក្ខណៈសមស្របឡើយ។ឧទាហរណ៍ការទទួលស្គាល់ការខាត បង់តម្លៃអាចបង្ហាញថា រយៈពេលនៃការធ្វើរំលស់ត្រូវធ្វើការផ្លាស់ប្តូរ ។

១០៦ ពេញមួយការិយបរិច្ឆេទគំរូ នៃផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលបានរំពឹងថា នឹងហូរចូល ទៅក្នុងអង្គភាពដែលផលប្រយោជន៍នោះកើតឡើងពីទ្រព្យសកម្មអរូបិយអាចផ្លាស់ប្តូរ ។ ឧទាហរណ៍ វាអាចក្លាយទៅជាការបង្ហាញឱ្យឃើញថា វិធីសាស្ត្ររំលស់នៃការបន្ថយសមតុល្យ វាទំនងជាសមហេតុផល ជាងវិធីសាស្ត្ររំលស់ថេរ ។ ឧទាហរណ៍ មួយទៀត គឺប្រសិនបើ ប្រើប្រាស់សិទ្ធិដែលតំណាងដោយអាជ្ញាប័ណ្ណមួយត្រូវបានពន្យាររង់ចាំសកម្មភាព លើសមាសភាពផ្សេងទៀតនៃ ផែនការអាជីវកម្ម ។ ក្នុងករណីនេះ ផលប្រយោជន៍សេដ្ឋកិច្ចដែល ហូរពីទ្រព្យសកម្ម អាចមិនត្រូវទទួលបានរហូតដល់ពេលក្រោយ ។

**ទ្រព្យសកម្មអរូបិយដែលមានអាយុកាលមិនអាចកំណត់បាន**

**១០៧ ទ្រព្យសកម្មអរូបិយដែលមានអាយុកាលប្រើប្រាស់ មិនអាចកំណត់បានមិនត្រូវ បានធ្វើរំលស់ទេ។**

១០៨ យោងតាម ស.គ.អ.ក ៣៦ អង្គភាពមួយ ត្រូវបានទាមទារ ឱ្យធ្វើការធ្វើតេស្តនូវទ្រព្យអរូបិយរបស់ខ្លួន ដែលមានអាយុកាលមិនអាចកំណត់បានសម្រាប់ការខាតបង់តម្លៃដោយប្រៀបធៀបជាមួយនឹងចំនួនទឹកប្រាក់ដែលស្រង់បានមកវិញ ជាមួយនឹងតម្លៃយោង ។

(ក) ជាប្រចាំឆ្នាំ និង

(ខ) នៅពេលណាក៏ដោយឱ្យតែមានសញ្ញាបង្ហាញថាទ្រព្យសកម្ម អរូបិយអាចនឹងមានការខាតបង់តម្លៃ។

**ការត្រួតពិនិត្យមើលឡើងវិញនៃការវាយតម្លៃអាយុកាលប្រើប្រាស់**

**១០៩ អាយុកាលប្រើប្រាស់របស់ទ្រព្យអរូបិយដែលមិនត្រូវបានធ្វើរំលស់ នឹងត្រូវធ្វើ ការត្រួតពិនិត្យឡើងវិញ នៅរាល់ចុងការិយបរិច្ឆេទដើម្បីកំណត់ថាតើមាន ព្រឹត្តិការណ៍និងកាលៈទេសៈនៅតែបន្ត ដើម្បីគាំទ្រដល់ការវាយតម្លៃពីអាយុកាល នៃទ្រព្យសកម្មមិនអាចកំណត់បានដែរឬទេ ។ ប្រសិនបើ ទ្រព្យសកម្មទាំងនោះមិនមានទេនោះការផ្លាស់ប្តូរការវាយតម្លៃអាយុកាលពី មិនអាចកំណត់បានទៅជាកំណត់បាននឹងត្រូវបានធ្វើគណនេយ្យកម្មជាការប៉ាន់ស្មានគណនេយ្យ ដោយយោង តាម ស.គ.អ.ក ៨ ។**

១១០ យោងតាម ស.គ.អ.ក ៣៦ ការវាយតម្លៃអាយុកាលនៃទ្រព្យអរូបិយឡើងវិញ ជាអាយុកាលអាចកំណត់បាន ជាជាងមិនអាចកំណត់បាន គឺជាសូចនាករ មួយដែលបង្ហាញឱ្យឃើញថាទ្រព្យសកម្មអាចថយចុះនៃតម្លៃ។ ជាលទ្ធ

ផល អង្គភាពធ្វើតេស្ត អំពីភាពថយចុះនៃតម្លៃ ដោយប្រៀបធៀបតម្លៃដែលអាច ស្រង់បាន (ដែលបានកំណត់ដោយ ស.គ.អ ៣៦) ជាមួយនឹងតម្លៃយោង ហើយការទទួលស្គាល់ទឹកប្រាក់លើសណាមួយនៃតម្លៃយោងលើតម្លៃដែលអាចស្រង់បាន វាគឺជាទឹកប្រាក់ខាតបង់ដោយសារការថយចុះនៃតម្លៃ ។

## លទ្ធភាពអាចស្រង់បាននៃតម្លៃយោង-ការខាតបង់ដោយសារការថយចុះនៃតម្លៃ

១១១ ដើម្បីកំណត់ថា តើទ្រព្យសកម្មអរូបិយចុះថយតម្លៃ អង្គភាពមួយត្រូវអនុវត្តតាម ស.គ.អ.ក ៣៦ ។ ស្តង់ដានោះ ពន្យល់ពីពេលវេលានិងរបៀបដែលអង្គភាពមួយពិនិត្យឡើងវិញ នូវតម្លៃយោងរបស់ទ្រព្យសកម្មនោះ ពន្យល់ពីរបៀបកំណត់តម្លៃដែលអាចស្រង់មកវិញបានរបស់ទ្រព្យសកម្ម និងពីពេលដែលត្រូវទទួលស្គាល់ឬត្រឡប់មកវិញនូវការខាតបង់ដោយការថយចុះនៃតម្លៃនោះ ។

## ការអស់អាយុកាលប្រើប្រាស់ និងការលក់ចេញ

**១១២ ទ្រព្យសកម្មអរូបិយមួយត្រូវបានឈប់ទទួលស្គាល់:**

**(ក) នៅក្នុងពេលលក់ចេញ។ ឬ**

**(ខ) ពេលដែលពុំគ្មានផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ត្រូវបានគេរពឹងថានឹងទទួលបានពីការប្រើប្រាស់ និងការលក់ចេញ។**

**១១៣ ចំណេញ ឬ ខាត ដែលកើតឡើងពីការឈប់ទទួលស្គាល់ទ្រព្យសកម្មអរូបិយត្រូវបានកំណត់ជាភាពខុសគ្នារវាងចំណូលពីការលក់ពិត និងតម្លៃយោងនៃ**

**ទ្រព្យសកម្មនោះប្រសិនបើមាន។ ភាពខុសគ្នានោះត្រូវបានទទួលស្គាល់ថាក្នុងរបាយការណ៍ចំណេញ-ខាត នៅពេលដែលទ្រព្យសកម្មនោះ ត្រូវបានឈប់ទទួលស្គាល់ (លើកលែងតែ ស.គ.អ.ក ១៧ ភតិសន្យា តម្រូវឱ្យមានការលក់ និងជួលត្រឡប់មកវិញ)។ ចំណេញនឹងមិនត្រូវបានចាត់ថ្នាក់ ជាផលរបរទេ។**

១១៤ ការលក់នៃទ្រព្យអរូបិយមួយអាចនឹងកើតឡើងដោយមធ្យោបាយផ្សេងៗ (ឧទាហរណ៍ ដោយលក់ ដោយការចាត់បញ្ចូលទៅក្នុងភតិសន្យាហិរញ្ញវត្ថុ ឬដោយការផ្តល់ជំនួយ)។ការកំណត់អំពីកាលបរិច្ឆេទនៃការលក់ទ្រព្យសកម្មមួយ អង្គភាពត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យទៅតាម ស.គ.អ.ក ១៨*ផលរបរ* សម្រាប់ការទទួលស្គាល់ផលរបរដែលបានមកពីការលក់ទំនិញ។ ស.គ.អ.ក ១៧អនុវត្តចំពោះការលក់ចោលដោយការលក់និងការជួលត្រឡប់មកវិញ។

១១៥ ដោយយោងតាមគោលការណ៍ទទួលស្គាល់នៅក្នុងកថាខណ្ឌ ២១ អង្គភាពមួយ ទទួលស្គាល់តម្លៃយោងនៃទ្រព្យសកម្មតាមថ្លៃដើមជំនួសផ្នែកសម្រាប់ផ្នែកទ្រព្យសកម្មអរូបិយបន្ទាប់មកឈប់ទទួលស្គាល់តម្លៃយោង នៃផ្នែកជំនួស នោះវិញ ។ ប្រសិនបើអង្គភាពមិនអាចអនុវត្តបានដើម្បីកំណត់តម្លៃយោងនៃ ផ្នែកដែលជំនួសនោះទេ គេអាចប្រើថ្លៃដើមជំនួសធ្វើជាសូចនករដើម្បី បង្ហាញនូវអ្វីដែលថ្លៃដើមនៃផ្នែកបានជំនួសនៅពេលវាត្រូវបានទិញឬត្រូវ បានបង្កើតឡើងពីខាងក្នុង ។

១១៥ក នៅក្នុងករណីនៃសិទ្ធិដែលបានទិញម្តងទៀតនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា ប្រសិនបើសិទ្ធិត្រូវបានបោះផ្សាយជាបន្តបន្ទាប់ (លក់) ទៅឱ្យភាគីទី៣

នៅតម្លៃយោងទាក់ទិន ត្រូវបានប្រើនៅក្នុងការកំណត់ពីចំណេញឬខាត លើការបោះផ្សាយឡើងវិញ ប្រសិនបើមាន។

១១៦ តម្លៃតបស្នងនឹងត្រូវទទួល ស្តីពីការលក់នៃទ្រព្យអរូបិយ ត្រូវទទួលស្គាល់ជាលើកដំបូងនៅតាមតម្លៃសមស្រប ។ ប្រសិនបើ ទូទាត់សម្រាប់ទ្រព្យ អរូបិយត្រូវបានពន្យាពេល តម្លៃតបស្នងនឹងត្រូវទទួលត្រូវបានទទួលស្គាល់ដំបូង ជាសាច់ប្រាក់សមមូល ។ ភាពខុសគ្នារវាងទឹកប្រាក់ធម្មតានៃតម្លៃតបស្នង និងតម្លៃសាច់ប្រាក់សមមូល ត្រូវបានទទួលស្គាល់ជាផលរបរពីការប្រាក់ ដោយយោងតាម ស.គ.អ.ក ១៨ ឆ្លុះបញ្ចាំងពីចំណូលប្រសិទ្ធិភាពលើគណនីត្រូវទទួល ។

១១៧ ការរំលស់នៃទ្រព្យអរូបិយដែលមានអាយុកាលអាចកំណត់បានមិនមានការបញ្ឈប់ទេ នៅពេលដែលទ្រព្យអរូបិយមិនត្រូវបានប្រើប្រាស់តទៅទៀត លើកលែងតែទ្រព្យសកម្មត្រូវបានរំលស់អស់ ឬត្រូវបានចាត់ថ្នាក់សម្រាប់លក់វិញ (ឬបានបញ្ចូលនៅក្នុងក្រុមសម្រាប់លក់ ដែលចាត់ថ្នាក់សម្រាប់លក់) យោងតាម ស.រ.ហ.អ.ក ៥ ។

## ការលាតត្រដាងព័ត៌មានទូទៅ

**១១៨ អង្គភាពមួយត្រូវលាតត្រដាងនូវចំណុចដូចខាងក្រោម ចំពោះចំណាត់ថ្នាក់នីមួយៗ របស់ទ្រព្យសកម្មអរូបិយ ហើយត្រូវញែកឱ្យដាច់រវាងទ្រព្យសកម្មអរូបិយដែលបានបង្កើតពីខាងក្នុងអង្គភាព និងទ្រព្យសកម្មអរូបិយដទៃទៀត:**

**(ក) ថាតើអាយុកាលប្រើប្រាស់ត្រូវបានកំណត់ថាមានកាលកំណត់ ឬមិនអាចកំណត់បាន និងប្រសិនបើអាចកំណត់បានត្រូវបង្ហាញពីអាយុកាលប្រើប្រាស់ ឬអត្រារំលស់ត្រូវបានប្រើ ។**

(ខ) វិធីសាស្ត្ររំលស់ដែលបានប្រើសម្រាប់ទ្រព្យអរូបិយជាមួយនិងការកំណត់ពីអាយុកាលប្រើប្រាស់ ។

(គ) តម្លៃយោងសរុបនិងតម្លៃរំលស់បូកបន្ត (បូកទាំងការខាតបង់ដោយសារការធ្លាក់ចុះនៃតម្លៃបូកបន្ត)នៅដើមនិងចុងការិយបរិច្ឆេទ។

(ឃ) ធាតុដែលមាននៅក្នុងរបាយការណ៍លទ្ធផលលម្អិត ដែលរំលស់នៃទ្រព្យសកម្មអរូបិយ ត្រូវបានដាក់បញ្ចូល ។

(ង) ការផ្ទៀងផ្ទាត់នៃតម្លៃយោងនៅដើម និងចុងការិយបរិច្ឆេទ ដោយបង្ហាញពីៈ

(១) ការទិញបន្ថែម ចង្អុលបង្ហាញធាតុដែលទិញបន្ថែមនោះដាច់ដោយឡែកពីការអភិវឌ្ឍ ដោយផ្ទៃក្នុង និងតម្រូវដាច់ពីគ្នា និងតាមរយៈការបញ្ចូលអាជីវកម្មរួមគ្នា

(២) ទ្រព្យសកម្មដែលចាត់ថ្នាក់សម្រាប់ការលក់ ឬរួមទាំងក្រុមសម្រាប់លក់ដែលបានចាត់ថ្នាក់ សម្រាប់ការលក់ដោយយោងតាម ស.រ.ហ.អ.ក ៥ និងការលក់ដទៃទៀត

(៣) ការកើនឡើង ឬថយចុះ ក្នុងអំឡុងពេលវាយតម្លៃនៅក្រោមកថាខណ្ឌ ៧៥ ៨៥ និង ៨៦ និងពីការខាតបង់ដោយសារការធ្លាក់ចុះនៃតម្លៃឬដែលបានកត់ត្រាបញ្ច្រាស់មកវិញ នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀតយោងតាម ស.គ.អ.ក៣៦ (ប្រសិនបើមាន)

(៤) ការខាតបង់ដែលបានទទួលស្គាល់នៅ ក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទ យោងតាមស.គ.អ.ក ៣៦ ប្រសិនបើមាន

(៥) ការខាតបង់ដោយសារការធ្លាក់ចុះនៃតម្លៃ ដែលត្រូវបានកត់ត្រាបញ្ច្រាស់មកវិញ ក្នុងរបាយការណ៍លទ្ធផលក្នុងគ្រា យោងតាម ស.គ.អ.ក ៣៦ប្រសិនបើមាន

(៦) ទឹកប្រាក់រំលស់ណា ដែលបានទទួលស្គាល់ក្នុងគ្រា

(៧) ការខុសគ្នាពិត ដែលកើតចេញពីប្រែសំរួលនៃរបាយការណ៍ហិរញ្ញវត្ថុទៅជា រូបិយប័ណ្ណបង្ហាញ និងប្រែសម្រួលសម្រាប់កិច្ចប្រតិបត្តិការបរទេស ទៅជារូបិយប័ណ្ណបង្ហាញរបស់អង្គភាព និង

(៨) ការផ្លាស់ប្តូរដទៃទៀតក្នុងតម្លៃយោងក្នុងការិយបរិច្ឆេទ ។

១១៩ ចំណាត់ថ្នាក់នៃទ្រព្យសកម្មអរូបិយគឺជាក្រុមនៃទ្រព្យសកម្ម ដែលមានលក្ខណៈ និងការប្រើប្រាស់ស្រដៀងគ្នានៅក្នុងកិច្ចប្រតិបត្តិការរបស់អង្គភាព។ ឧទាហរណ៍នៃចំណាត់ថ្នាក់ដោយឡែកៗពីគ្នា អាចរួមមានៈ

(ក) ស្លាកយីហោ។

(ខ) ចំណងជើងនិងឈ្មោះនៃការបោះពុម្ពផ្សាយ ។

(គ) ផ្នែកទន់នៃកុំព្យូទ័រ។

(ឃ) អាជ្ញាប័ណ្ណ និងសិទ្ធិធ្វើពាណិជ្ជកម្មផ្តាច់មុខ។

(ង) សិទ្ធិចំលង ប្រកាសណីយប័ត្រ និងសិទ្ធិលើទ្រព្យសម្បត្តិខាងឧស្សាហកម្ម សេវាកម្ម និងសិទ្ធិកិច្ចប្រតិបត្តិការជំនួញ។

(ច) រូបមន្ត ក្បួន ម៉ូដែល គម្រោងប្លង់ និងគំរូដើម។

(ឆ) ទ្រព្យសកម្មអរូបិយកំពុងអភិវឌ្ឍន៍។

ចំណាត់ថ្នាក់ដែលបានរៀបរាប់ខាងលើ មិនត្រូវបូកបញ្ចូល (ឬត្រូវបូកបញ្ចូល) ទៅក្នុងចំណាត់ថ្នាក់តូចជាង (ធំជាង) ប្រសិនបើលទ្ធផលនេះមានព័ត៌មានទាក់ទិនច្រើនសម្រាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ។

១២០ អង្គភាពមួយ លាតត្រដាងព័ត៌មានស្តីពីការថយចុះនៃទ្រព្យអរូបិយដោយយោងតាម ស.គ.អ.ក ៣៦ បន្ថែមលើព័ត៌មានដែលតម្រូវដោយកថាខណ្ឌ ១១៨(ង)(៣)-(៥) ។

១២១ ស.គ.អ.ក ៨ តម្រូវឱ្យអង្គភាពលាតត្រដាងបង្ហាញប្រភេទ និងទឹកប្រាក់នៃការផ្លាស់ប្តូរការ ប៉ាន់ស្មានគណនេយ្យថា ផលប៉ះពាល់ជាសារវ័ន្តក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ឬត្រូវបានរំពឹងទុកថា មានផលប៉ះពាល់ជាសារវ័ន្តនៅការិយបរិច្ឆេទបន្តបន្ទាប់។ ការបង្ហាញទាំងនោះ អាចនឹងកើតចេញពីការផ្លាស់ប្តូរៈ

(ក) ការវាយតម្លៃអំពីអាយុកាលនៃទ្រព្យអរូបិយ ។

(ខ) វិធីសាស្រ្តរំលស់ ឬ

(គ) តម្លៃកាកសំណល់។

**១២២ អង្គភាពមួយត្រូវលាតត្រដាងបង្ហាញៈ**

**ក. សម្រាប់តម្លៃទ្រព្យសកម្មអរូបិយដែលបានវាយតម្លៃរួច ដែលមានអាយុកាលប្រើប្រាស់មិនអាចកំណត់បាន តម្លៃយោងនៃទ្រព្យសកម្មនោះ និងហេតុផលដែលគាំទ្រដល់ការវាយតម្លៃនៃអាយុកាលប្រើប្រាស់មិនអាចកំណត់បាន។ ក្នុងការផ្តល់ហេតុផលទាំងនេះ អង្គភាពនឹងពណ៌នាពីកត្តាដែលដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការកំណត់ថាទ្រព្យសកម្មមានអាយុកាលប្រើប្រាស់មិនអាចកំណត់បាន ។**

(ខ) ការបរិយាយតម្លៃយោងនិងការិយបរិច្ឆេទរំលស់នៅសល់ នៃទ្រព្យអរូបិយមួយៗ ដែលសារវ័ន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាព ។

(គ) សម្រាប់ទ្រព្យអរូបិយ ដែលបានមកពីជំនួយរដ្ឋាភិបាល និងបានទទួលស្គាល់ជាដំបូងនូវតម្លៃសមស្រប (សូមមើលកថាខណ្ឌ ៤៤)

(១) តម្លៃសមស្របដែលបានទទួលស្គាល់ជាដំបូងសម្រាប់ទ្រព្យសកម្មទាំងនេះ ។

(២) តម្លៃយោងរបស់ទ្រព្យសកម្ម និង

(៣) ថាតើពួកគេត្រូវបានវាស់វែងបន្ទាប់ពីមានការទទួលស្គាល់នៅក្រោមវិធីសាស្ត្រថ្លៃដើមឬវិធីសាស្ត្រការវាយតម្លៃឡើងវិញ។

(ឃ) ការកើតមានឡើង និងតម្លៃយោងនៃទ្រព្យសកម្មអរូបិយដែលកម្មសិទ្ធិទាំងនោះត្រូវបានរិតត្បិត និងតម្លៃយោងនៃទ្រព្យអរូបិយបានសន្យាជាការធានាសម្រាប់បំណុល ។

(ង) ទឹកប្រាក់នៃការសន្យាតាមកិច្ចសន្យាសម្រាប់ការទិញទ្រព្យអរូបិយ។

១២៣ នៅពេលដែលអង្គភាពមួយពណ៌នាពីកត្តាដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ អំពីអាយុកាល ប្រើប្រាស់នៃទ្រព្យអរូបិយមិនអាចកំណត់បាន អង្គភាពធ្វើការពិចារណានូវបញ្ជីនៃទាំងឡាយ ដូចមានចែងនៅក្នុងកថាខណ្ឌ ៩០។

## ទ្រព្យសកម្មអរូបិយដែលបានវាស់វែងបន្ទាប់ពីការទទួលស្គាល់ដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃឡើងវិញ

១២៤ ប្រសិនបើទ្រព្យសកម្មអរូបិយ ត្រូវបានធ្វើគណនេយ្យកម្មតាមទឹកប្រាក់វាយតម្លៃឡើងវិញ នោះអង្គភាពត្រូវលាតត្រដាងបង្ហាញដូចខាងក្រោម:

(ក) តាមចំណាត់ថ្នាក់នៃទ្រព្យសកម្មអរូបីៈ

(១) ថ្ងៃចូលជាធរមាននៃការវាយតម្លៃឡើងវិញ

(២) តម្លៃយោងនៃការវាយតម្លៃទ្រព្យសកម្មអរូបិយឡើងវិញ និង

(៣) តម្លៃយោងដែលគួរត្រូវបានទទួលស្គាល់ មានចំណាត់ថ្នាក់ទ្រព្យសកម្មអរូបិយវាយតម្លៃរួច ត្រូវបានវាស់វែងបន្ទាប់ពីការទទួលស្គាល់ដោយប្រើប្រាស់វិធីសាស្ត្រថ្លៃដើមដូចមានក្នុង កថាខណ្ឌ ៧៤ ។

(ខ) ទឹកប្រាក់ពីអតិរេកពីការវាយតម្លៃ ដែលទាក់ទងនឹងទ្រព្យសកម្មអរូបិយនាដើមគ្រា និងចុងគ្រា ដែលចង្អុលបង្ហាញពីការផ្លាស់ប្តូរក្នុងការិយបរិច្ឆេទ និងការរិតត្បិតលើការបែងចែង សមតុល្យទៅម្ចាស់ហ៊ុនហើយ

(គ) វិធីសាស្ត្រ និងការសន្មតសំខាន់ៗ ដែលត្រូវអនុវត្តនៅក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃទ្រព្យសកម្ម ។

១២៥ អាចមានភាពចាំបាច់នៅក្នុងបូកសរុបចំណាត់ថ្នាក់នៃទ្រព្យសកម្មដែលវាយតម្លៃឡើងវិញទៅតាមចំណាត់ថ្នាក់ធំៗ សម្រាប់ជាគោលបំណងនៃការធ្វើការលាតត្រដាងបង្ហាញ ។ ទោះជាយ៉ាងណាក៏ដោយចំណាត់ថ្នាក់មិនត្រូវបានបូកសរុបទេប្រសិនបើវានឹងផ្តល់លទ្ធផលនៃការបញ្ចូលគ្នានៃថ្នាក់ទ្រព្យសកម្មអរូបិយដែលរួមបញ្ចូលទាំងទឹកប្រាក់ដែលវាស់វែងស្ថិតក្រោមវិធីសាស្ត្រថ្លៃដើម និងវិធីសាស្ត្រវាយតម្លៃឡើងវិញ។

**ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍**

**១២៦ អង្គភាពមួយ ត្រូវលាតត្រដាងបង្ហាញនូវទឹកប្រាក់សរុបនៃការចំណាយទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍ ដែលបានទទួលស្គាល់នៅក្នុងគ្រា ។**

១២៧ ចំណាយទៅលើការស្រាវជ្រាវនិងការអភិវឌ្ឍរួមមានចំណាយទាំងអស់ដែលផ្តល់ដោយផ្ទាល់ដល់សកម្មភាពការស្រាវជ្រាវ និងការអភិវឌ្ឍ (សូមមើលកថាខណ្ឌ ៦៦-៦៧ សម្រាប់ការណែនាំស្តីអំពីប្រភេទនៃចំណាយដែលត្រូវបានបញ្ចូលសម្រាប់គោលបំណងនៃសេចក្តីតម្រូវឱ្យមានការលាតត្រដាងបង្ហាញនៅក្នុង កថាខណ្ឌ ១២៦) ។

**ព័ត៌មានផ្សេងទៀត**

១២៨ អង្គភាពមួយត្រូវលើកទឹកចិត្តប៉ុន្តែមិនបានតម្រូវទេឱ្យលាតត្រដាងព័ត៌មានដូចខាងក្រោមៈ

(ក) ការពិពណ៌នាពីទ្រព្យសកម្មអរូបិយដែលមានរំលស់អស់ទាំងស្រុងដែលនៅបន្តការប្រើប្រាស់ និង

(ខ) ការពិពណ៌នាដោយសង្ខេបនៃទ្រព្យសកម្មអរូបិយសំខាន់ៗ ដែលគ្រប់គ្រងដោយអង្គភាពប៉ុន្តែមិនត្រូវបានទទួលស្គាល់ ជាទ្រព្យសកម្មឡើយ ពីព្រោះពួកគេមិនបានបំពេញនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ ក្នុងស្តង់ដានេះ ឬដោយសារតែទ្រព្យសកម្មអរូបិយទាំងនោះត្រូវបានទិញឬទទួលបានមុនពេល ស.គ.អ.ក ៣៨ *ទ្រព្យសកម្មអរូបិយ* ដែលបានចេញផ្សាយឱ្យប្រើប្រាស់នៅក្នុងឆ្នាំ១៩៩៨ ។

**អន្តរបញ្ញត្តិ និង កាលបរិច្ឆេទចូលជាធរមាន**

---

១២៩ [លុបចោល]

១៣០ អង្គភាពត្រូវប្រើស្តង់ដារនេះ

(ក) ចំពោះការធ្វើគណនេយ្យកម្មសម្រាប់ទ្រព្យសកម្មអរូបិយដែលបានទិញនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា សម្រាប់កាលបរិច្ឆេទកិច្ចព្រមព្រៀងនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៤ និង

(ខ) ចំពោះការធ្វើគណនេយ្យកម្ម សម្រាប់ទ្រព្យសកម្មអរូបិយទាំងអស់ផ្សេងទៀតទៅថ្ងៃខាងមុខ ចាប់ពីដើមការិយបរិច្ឆេទប្រចាំឆ្នាំដំបូងដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៤។ ដូច្នេះ អង្គភាពមិនត្រូវកែសម្រួលតម្លៃយោងនៃទ្រព្យសកម្មអរូបិយដែល បានទទួលស្គាល់នៅថ្ងៃនោះទេ។ ក៏ប៉ុន្តែ នៅថ្ងៃនោះ អង្គភាពត្រូវប្រើស្តង់ដារនេះដើម្បី វាយតម្លៃឡើងវិញពីអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មបែបនេះ។ ប្រសិនបើ ជាលទ្ធផលនៃការវាយតំម្លៃ ឡើងវិញនោះ អង្គភាពផ្លាស់ប្តូរការវាយតម្លៃនៃអាយុកាលប្រើ ប្រាស់នៃទ្រព្យសកម្ម ការផ្លាស់ប្តូរនោះត្រូវបានធ្វើគណនេយ្យកម្មជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យដោយអនុលោមតាម ស.គ.អ.ក ៨។

១៣០ក អង្គភាពមួយត្រូវប្រើវិសោធនកម្មនៅក្នុងកថាខណ្ឌ២សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៦។ ប្រសិនបើអង្គភាពប្រើ ស.រ.ហ.អ.ក ៦ សម្រាប់គ្រាមុន វិសោធនកម្មទាំងនោះត្រូវបានប្រើសម្រាប់ការិយបរិច្ឆេទមុននោះ។

១៣០ខ ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (ដូចបានកែប្រែក្នុងឆ្នាំ ២០០៧) បានធ្វើវិសោធនកម្មវាក្យសព្ទដែលបានប្រើពេញ ស.រ.ហ.អ.ក។ លើសពីនេះទៅទៀត អង្គភាពបានធ្វើវិសោធនកម្មកថាខណ្ឌ ៨៥ ៨៦ និង ១១៨ (ង)(៣)។ អង្គភាពមួយត្រូវប្រើវិសោធនកម្មទាំងនោះសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០០៩។ ប្រសិនបើអង្គភាពអនុវត្ត ស.គ.អ.ក ១ (បានកែប្រែឆ្នាំ២០០៧) សម្រាប់គ្រាមុន វិសោធនកម្មត្រូវបានប្រើសម្រាប់គ្រាមុននោះ។

១៣០គ ស.រ.ហ.អ.ក (ដូចបានកែប្រែនៅក្នុងឆ្នាំ ២០០៨) បានធ្វើវិសោធនកម្មកថាខណ្ឌ ១២ ៣៣-៣៥ ៦៨ ៦៩ ៩៤ និង ១៣០ លុបចោលកថាខណ្ឌ ៣៨ និង ១២៩ និង បន្ថែមកថាខណ្ឌ ១១៥ក។ *ការធ្វើឱ្យប្រសើរឡើងចំពោះស.រ.ហ.អ.ក* ដែលបានបោះផ្សាយនៅក្នុងខែមេសា ឆ្នាំ២០០៩ បានធ្វើវិសោធនកម្មកថាខណ្ឌ ៣៦ និង ៣៧។ អង្គភាពមួយត្រូវបានប្រើវិសោធនកម្ម ទាំងនោះទៅថ្ងៃខាងមុខសម្រាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ដូច្នេះ ទឹកប្រាក់ដែលបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មអរូបិយ និងមូលនិធិពាណិជ្ជកម្មនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាពីមុនមិនត្រូវបានកែសំរួលទេ។ ប្រសិនបើអង្គភាពប្រើ ស.រ.ហ.អ.ក ៣ (បានកែប្រែក្នុងឆ្នាំ២០០៨) សម្រាប់គ្រាមុន អង្គភាពត្រូវប្រើវិសោធនកម្មសម្រាប់គ្រាមុននោះ និងលាតត្រដាងពីហេតុការណ៍នោះផងដែរ។

១៣០ឃ កថាខណ្ឌ៦៩ ៧០ និង ៩៨ ត្រូវបានធ្វើវិសោធនកម្ម និង កថាខណ្ឌ ៦៩ ក ត្រូវបានបន្ថែម ដោយ*ការធ្វើឱ្យប្រសើរឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយនៅក្នុងខែឧសភា ឆ្នាំ២០០៨។ អង្គភាពមួយត្រូវប្រើ

វិសោធនកម្មទាំងនោះសម្រាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទីឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាត្តិ។ ប្រសិនបើអង្គភាពអនុវត្តវិសោធនកម្មសម្រាប់គ្រាមុនអង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ។

១៣០ង *ការធ្វើឱ្យប្រសើឡើងចំពោះ ស.រ.ហ.អ.ក* ដែលបានចេញផ្សាយនៅក្នុងខែមេសា ឆ្នាំ២០០៩ បានធ្វើវិសោធនកម្មកថាខណ្ឌ ៤០ និង ៤១។ អង្គភាពមួយត្រូវអនុវត្តវិសោធនកម្មទាំងនោះទៅថ្ងៃខាងមុខសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទីឬបន្ទាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាតិ។ ប្រសិនបើអង្គភាពមួយប្រើវិសោធនកម្មសម្រាប់ការិយបរិច្ឆេទមុនអង្គភាពត្រូវលាតត្រដាងពីហេតុការណ៍នោះ។

## ការដោះដូរទ្រព្យសកម្មស្រដៀងគ្នា

១៣១ សេចក្តីតម្រូវនៅក្នុងកថាខណ្ឌ ១២៩ និង ១៣០(ខ) ដើម្បីប្រើស្តង់ដារនេះទៅថ្ងៃខាងមុខមានន័យថា ប្រសិនបើការដោះដូរទ្រព្យសកម្មត្រូវបានវាស់វែងមុនកាលបរិច្ឆេទប្រសិទ្ធិភាពនៃស្តង់ដារនេះតាមមូលដ្ឋាននៃតម្លៃយោងនៃទ្រព្យសកម្មដែលបានបោះបង់ចោល អង្គភាពមិនត្រូវ បង្ហាញឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មដែលបានទិញដើម្បីឆ្លុះបញ្ចាំងពីតម្លៃសមស្របនៅ កាលបរិច្ឆេទទិញនោះទេ។

## ការអនុវត្តមុន

១៣២ អង្គភាពទាំងឡាយដែលអនុវត្តកថាខណ្ឌ ១៣០ ត្រូវបានលើកទឹកចិត្តដើម្បីប្រើសេចក្តីតម្រូវនៃ ស្តង់ដារនេះមុនកាលបរិច្ឆេទប្រសិទ្ធិភាពដែលបាន

បញ្ជាក់នៅក្នុងកថាខណ្ឌ១៣០។ ប៉ុន្តែ ប្រសិនបើអង្គភាពប្រើស្តង់ដារនេះ មុនកាលបរិច្ឆេទប្រសិទ្ធិទាំងនោះ អង្គភាពក៏ត្រូវប្រើ ស.រ.ហ.អ.ក ៣ និង ស.គ.អ.ក ៣៦ (ដូចបានកែប្រែក្នុងឆ្នាំ២០០៨) នៅពេលជាមួយគ្នា។

## ការដកចេញនៃ ស.គ.អ.ក ៣៨ (១៩៩៨)

១៣៣ ស្តង់ដារនេះជំនួសឱ្យ ស.គ.អ.ក ៣៨ *ទ្រព្យសកម្មអរូបិយ* (ចេញផ្សាយនៅក្នុងឆ្នាំ ១៩៩៨)។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ